ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ៩

ខ្សែ ៣

កុម្ស៊ីយ៍សេនាបតីបានឧទ្ទិសហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨០

គ.ស. ១៩៣៧

ក្រុមជំនុំទំនៀមទម្លាប់

COMMISSION DES MŒURS & COUTUMES

# បញ្ជីរឿង


ទំព័រ

១ ខេមរខេមសរណកថា ត្រង់សំដែងអំពីធម្មសរណ សង្ឃសរណ និងវិធីដល់ព្រះ ត្រៃសរណគមន៍ ព្រះមហាពិទូរ ក្រសេម រៀបរៀង (ត) .......... ៣

២ គាថាធម្មបទ ប្រែ .......................... ១៩

៣ លោកន័យ ពាក្យកាព្យ (ត) .................. ៧៩

៤ ល្បើកច្បាប់សង្ឃ ក្រមង៉ុយតែង (ចប់) ............. ១០៥


::

# រូបក្រៅរឿង


១ ចេតិយ ព្រះ ៨៨០ នៅក្រុងមណ្ឌលេ (ភូមា)............ ១

២ កូនសិស្សលោកសង្ឃ នៅស្រុកភូមា រែកសម្រាប់មកពីភូមិ ទោរត្ន..... ៧៧

# TABLE DES MATIÈRES

I. Khemā-Khema Saranakathā ou Religion, refuge des hommes . . . . . . . . . . 3

II. Gāthādhammapada traduit du Pāli en Cambodgien . . . . . 19

III. Lokanaya . . . . . . . . . . 79

IV. Paroles de Krom Ngoy . . . . . . . . . . 105

## HORS TEXTE:

I. Le Chedi aux 880 statues du Bouddha Mandalay-Birmanie. - 1

II. Un élève de la Pagode revenant de la quête de nouriture.

Pagan-Birmanie . . . . . . . . . . 77



ចេតិយព្រះ ៨៨០ អង្គ នៅក្រុងមណ្ឌលេ (ភូមា) ។

ខេមរាខេមរសារណាកថា

# ព្រះមហាពិទូរ ក្រសេម គន្ថរបនបណ្ឌិត

រៀបរៀង (ត)

## ព្រះធម្មសារណា:

ព្រះធម៌ដែលនឹងនាំមកថ្លែងតទៅនេះតែដោយសង្ខេប ជាព្រះពុទ្ធដីកានៃព្រះបរមសាស្ដា ដែលព្រះអង្គទ្រង់ជ្រាបដោយគម្ពីរញ្ញាណ ហើយទ្រង់នាំទៅប្រដៅប្រជាជនក្នុងទីនោះៗ ក្នុងកាលនោះៗ, គោលសំខាន់គឺទ្រង់បំណងនឹងឲ្យបំពេញសេចក្ដីល្អ លះសេចក្ដីអាក្រក់ផ្លូវកាយវាចាចិត្ត ឲ្យទៅជាបុគ្គលសុភាពរៀបរយ ក្នុងជាន់ដើមគឺឲ្យស្គាល់ថា អ្វីជាហេតុ អ្វីជាផលដើម្បីនឹងបានតាំងខ្លួនទុកក្នុងផ្លូវដ៏ប្រពៃ ឲ្យប្រសព្វតែផលដែលជាសុខសម្រាន ចៀសចាកផ្លូវទុក្ខក្ដៅក្រហាយ, ឲ្យស្គាល់ខ្លួនរបស់ខ្លួនថា តាំងនៅក្នុងឋានៈត្រឹមណា ហើយប្រព្រឹត្តជម្រើតាមជាន់ខ្ពស់ទាបរបស់ខ្លួនមិនឲ្យផ្គង, ឲ្យស្គាល់មាត្រាតែល្មមក្នុងការស្វែងរក ការទទួល បរិភោគ មិនឲ្យហួសប្រមាណ, ឲ្យស្គាល់កាលវេលាសម្រាបនឹងប្រកបកិច្ចផ្សេងៗ ដើម្បីនឹងឲ្យចំរើនផលប្រយោជន៍បរិបូណ៌, ឲ្យស្គាល់ទំនិមទំនៀមក្នុងវេលាទៅរកអ្នកណា ឬក្នុងវេលាអ្នកណាមករកខ្លួន កុំឲ្យខូចកិរិយា, ឲ្យស្គាល់មនុស្សអាក្រក់ល្អ ដើម្បីចៀសក្ដីអន្តរាយក្នុងការគប់ ។

មួយទៀតប្រដៅឱ្យបំពេញប្រយោជន៍ ៣ ជាន់ បីដូចជាជណ្ដើរ ៣ ជាន់

ជាន់ទី ១ ក- ឧស្សាហ៍ក្នុងការស្វែងរកទ្រព្យសម្បត្តិ ការសិក្សារៀនសូត្រ ការធ្វើកិច្ចនីមួយ ។ល។ ខ- ការរក្សាទ្រព្យឬបំណេះវិជ្ជាដែលរកបានមកដោយព្យាយាមនោះ ឱ្យគង់នៅកុំឱ្យខូចខាត, គ- គប់តែមិត្រដែលល្អ, ឃ- ចិញ្ចឹមជីវិតតែល្មមនឹងកំលាំងទ្រព្យដែលរកបាន មិនឱ្យខ្ជះខ្ជាយណាស់ មិនឱ្យត្បិតត្បៀតណាស់ ។

ជាន់ទី២ ក- ជឿក្នុងធម៌ដែលគួរជឿ, ខ- ប្រព្រឹត្តកាយវាចាឱ្យគួរដល់ប្រក្រតី យ៉ាងទាបត្រឹមរក្សាសីលប្រាំ, គ- បរិចាគទ្រព្យរបស់ខ្លួនឱ្យជាប្រយោជន៍ដល់អ្នកដទៃ មិនឱបក្រសោបបរិភោគតែម្នាក់ឯង, ឃ- ដឹងស្គាល់ក្នុងរឿងដែលគួរដឹងគួរស្គាល់ ដូចយ៉ាងគតិនៃធម្មតា, ផ្លូវសាបសូន្យ ផ្លូវចំរើន ។

ជាន់ទី ៣ ជាប្រយោជន៍យ៉ាងកំពូល គឺឱ្យដឹងប្រក្រតីនៃចិត្តនឹងគ្រឿងសៅហ្មងរបស់ចិត្តថា មានយ៉ាងម្ដេចខ្លះ ឱ្យស្គាល់សាមញ្ញលក្ខណដែលជាក្រិត្យធម្មតាថា បណ្ដារបស់

ដែលអាស្រ័យហេតុបច្ច័យកើតឡើង សុទ្ធសឹងតែជាទុក្ខទាំងអស់, គ្មានអ្វីទៀងទាត់គង់ទី, មិនមែនខ្លួនមិនជាខ្លួន, ហើយធ្វើទុកក្នុងចិត្តដោយយោនិសោមនសិការ ដើម្បីនឹងផ្គុំគ្នាឲ្យត្រង់នឹងសេចក្ដីដឹងដោយថាភូតញ្ញាណទស្សនៈ គឺដឹងឃើញតាមដែលកើតមកដូចម្ដេច ទាល់តែចិត្តរសាយផុតអំពីគ្រឿងសៅហ្មងទាំងនោះ រាប់ជាស្រេចកិច្ចរបស់ជីវិតដ៏ប្រកបដោយប្រយោជន៍ ៣ ជាន់ហើយដូចពណ៌នាមក នេះពោលខាងសត្យប្តិ ។

បំណែកខាងលះ ប្រដៅឲ្យលះវៀរអកុសលទុច្ចរិតបាបធម៌ដែលជាហេតុឲ្យកើតទោសក្នុងផ្លូវកាយវាចាចិត្ត ហើយគាស់រំលើងនូវឫសគល់នៃតណ្ហា ដោយដំណើរក្នុងបដិបទាផ្លូវកណ្ដាល គឺ អរិយមគ្គ ៨ ទាល់តែដល់នូវសេចក្ដីរលត់ទុក្ខទាំងអស់ជាទីបំផុត ។

តាមហេតុទាំងឡាយដែលបានពោលមក លោកទើបសរសើរគុណនៃព្រះធម៌ថា ស្វាក្ខាតោ ភគវតា ធម្មោ ព្រះធម៌សម្ដេចព្រះដ៏មានព្រះភាគទ្រង់សំដែងហើយល្អ ។ ក៏ព្រះធម៌នោះមានលក្ខណដូចពោលហើយខាងដើម តែក្នុងទីនេះព្រះ

អដ្ឋកថាចារ្យលោកបរិយាយទុកជាច្រើនប្រភេទ គឺព្រះបរិយត្តិធម៌បានដល់ពុទ្ធវចនទាំងមូល ដែលបុគ្គលគប្បីរៀនសូត្រទន្ទេញចងចាំទុក, ព្រះបដិបត្តិធម៌ បានដល់សីលសមាធិបញ្ញា ដែលជាគ្រឿងបង្វឹកកាយវាចាចិត្ត, ព្រះបដិវេធធម៌ បានដល់មគ្គផល និព្វាន ដែលជាធម៌សម្លាប់បង់នូវទុក្ខទាំងពួង អំពាលនេះបានឈ្មោះថា ស្វាក្ខាតធម៌ ជាធម៌ដែលព្រះអង្គទ្រង់ប្រកាសទុកហើយល្អទាំងអស់ តែបើនឹងពោលដោយសរុបហើយ ជាធម៌ប្រភេទណាក៏ដោយ បើប្រកបដោយគុណសម្បត្តិ ៥ ប្រការ តាមក្នុងបទព្រះធម្មគុណហើយទើបបានឈ្មោះថាស្វាក្ខាតធម៌ក្នុងទីនេះ. ធម្មគុណ ៥ ប្រការលោកអាងយកក្នុងបទ គឺ សន្ទិដ្ឋិកោ ព្រះធម៌នោះអ្នកបដិបត្តិអាចឃើញបានដោយខ្លួនឯង បើបដិបត្តិទៅហើយមិនឃើញបានដោយខ្លួនឯងសោតទេ ក៏មិនមែនជាស្វាក្ខាតធម៌របស់ព្រះដ៏មានព្រះភាគ, អកាលិកោ អ្នកបដិបត្តិធម៌ត្រឹមត្រូវហើយរមែងបានទទួលផលក្នុងខណៈបដិបត្តិនោះ មិនបាច់ចាំដល់ពេលនោះពេលនេះ, ឯហិបស្សិកោ ព្រះធម៌នោះរមែងស្ថិតនៅក្នុងចិត្តអ្នក

បដិបត្តិដោយពិត ដូចយ៉ាងមានវត្ថុនៅក្នុងកណ្ដាប់ដៃមាន អាការហាក់ដូចជានឹងស្រែកអញ្ជើញថា អ្នកអញ្ជើញចូលមក មើលចុះ ព្រោះជារបស់មានពិតៗ, ឱបនយិកោ ព្រះធម៌ នោះអ្នកបដិបត្តិអាចបង្អោនចូលមកកាន់ចិត្តនៃខ្លួនបាន, បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ព្រះធម៌នោះវិញ្ញូជនអ្នកបដិបត្តិដឹងបានចំពោះ ខ្លួន មិនបាច់ចាំលើកត្រៃរកគ្រូបកប្រែទៀតទេ ទាំង ៥ បទ នេះប្រកាសព្រះធម្មគុណ សំងជាកំពូលនៃធម៌ក្នុងលោក និង រកធម៌ក្នុងលទ្ធិឯណានីមួយមានគុណសារស្មើគ្មាន អ្នកបដិបត្តិ ត្រូវបរិបូណ៌ដោយសេចក្ដីមិនប្រមាទ និងសេចក្ដីតាំងចិត្តឲ្យ ខ្ជាប់ខ្ជួន ទើបប្រសព្វឧត្តមផលដូចពោលមក បើប្រសិនជាមិន ប្រាកដច្បាស់ក្នុងចិត្តថា ខបដិបត្តិនោះៗ ជាធម៌ឬមិនមែនធម៌ លោកឲ្យពិសោធ្យមើលដោយខមាត្រាជាគ្រឿងសម្រាប់នឹង វិនិច្ឆ័យដូចមានតទៅនេះ បើត្រូវតាមមាត្រានោះហើយ ទើប រាប់ថាព្រះធម៌ពិត គឺខធម៌ឯណាដែលបុគ្គលបដិបត្តិហើយ ប្រព្រឹត្តទៅដើម្បីរសាយរាគ, ដើម្បីមិនប្រកបដោយទុក្ខ, ដើម្បី មិនសន្សំនូវកិលេស, ដើម្បីប្រាថ្នាតិច, ដើម្បីសន្ដោស, ដើម្បី

ស្ងប់ស្ងាត់, ដើម្បីសេចក្ដីព្យាយាម, ដើម្បីចិញ្ចឹមងាយ, ជា ៨ ប្រការ កាលចូលក្នុងបទវិនិច្ឆ័យទាំង ៨ នេះឯណាទីមួយ ទើបរាប់ថាជាធម៌ជាវិន័យ ។ ព្រះធម៌ជារបស់ត្រជាក់ត្រជំ ជ្រឹតជ្រាបនៅក្នុងចិត្តអ្នកបដិបត្តិ អ្នកណាមិនប្រព្រឹត្ត អ្នកនោះរមែងក្ដៅក្រហាយ ថាបើប្រព្រឹត្តខ្លះទេខ្លះ ក៏ត្រជាក់ខ្លះ ក្ដៅក្រហាយខ្លះ, ក្នុងត្រកូលមួយ ៗ បើសុទ្ធតែជាអ្នកមិនប្រព្រឹត្តធម៌ទាំងអស់គ្នា ក៏គង់ជានឹងបែកគ្នាដោយមិនយូរ បើប្រព្រឹត្តធម៌ស្មើគ្នា រមែងបានសេចក្ដីសុខជានិរន្តរ, រហូតដល់ទៅប្រទេសនីមួយ ៗ ក៏ដូចគ្នានេះ, ភ័យអន្ដរាយមិនដែលកើតអំពីបណ្ឌិត-អ្នកមានធម៌, រមែងកើតតែអំពីបុគ្គលដែលគ្មានធម៌ ព្រោះហេតុនោះលោកទើបរាប់ព្រះធម៌ជាសរណៈប្រការ ១ ។

ព្រះសង្ឃសរណៈ

ព្រះពុទ្ធអង្គជាអ្នកសមគ្គរយុត្តិធម៌ស្មើភាគ មិនលើកកំ-ពស់ឬកៀរកោយប្រមូលមកលើព្រះអង្គតែមួយព្រះអង្គប៉ុណ្ណោះ សូម្បីព្រះធម៌ជាពាក្យប្រដៅរបស់ព្រះអង្គ ៗ ទ្រង់សំដែងដោយ

ខ្លួនឯង ព្រះសង្ឃក៏ជាសិស្សសាវករបស់ព្រះអង្គ ៗ មិនវង្វៀស
ទ្រង់លើកឡើងជាសរណៈស្មើគ្នានឹងព្រះអង្គ នឹងរកសាស្តា
ឯណាកាន់យុត្តិធម៌ស្មើភាគដូច្នេះគ្មាន ប្រើនកៀរកោបដាក់មក
លើខ្លួន សម្រេចលើខ្លួន ជាសេចក្តីមិនសុចរិតយុត្តិធម៌ ដែល
ទ្រង់លើកជាសរណៈស្មើគ្នាដូច្នេះ ជាអវិយុត្តិធម៌ ព្រោះវត្ថុទាំង
៣ នោះជារបស់តោងអាស្រ័យនូវគ្នានឹងគ្នា នឹងខាតខានឯណា
នីមួយមិនបានជាដាច់ខាត មិនកើតឡើងជាសាសនា ប្រៀប
ដូចជាកំណាត់ឈើ ៣ កំណាត់ បុគ្គលយកទៅបញ្ឈរផ្គុំបុង
ទល់គ្នាក៏អាចនឹងតាំងនៅបាន កាលបុគ្គលយក ១ កំណាត់
ចេញ ២ កំណាត់ទៀតក៏រលំ, យក ២ កំណាត់ចេញ ១ កំណាត់
ទៀតក៏រលំ, ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃតោងអាស្រ័យគ្នាដូច្នេះ
គឺថា កាលមានព្រះពុទ្ធត្រាស់ឡើងហើយ បើប្រសិនជា
មិនទ្រង់សំដែងធម៌ឲ្យអ្នកណាស្តាប់ ក៏គ្មានប្រយោជន៍អ្វីដល់
មនុស្ស ព្រះអង្គគង់ជានឹងចូលនិព្វានទៅតែមួយព្រះអង្គឯង
កាលព្រះអង្គទ្រង់សំដែងធម៌ហើយ តែបើប្រសិនជាគ្មានអ្នក
ណាស្តាប់បដិបត្តិតាមក៏ទទេទៀត សំដែងទៅក៏គ្រាន់តែកោកៗ

មិនខុសអ្វីនឹងត្រដោកគោអ្នកស្រុក តែនេះមិនដូច្នោះ អាស្រ័យព្រះមហាករុណាជាកំលាំង កាលព្រះអង្គបានត្រាស់ហើយ បានសំដែងសាសនធម៌បង្អុលផ្លូវអាក្រក់ផ្លូវល្អ ដែលមិនគួរដំណើរនឹងគួរដំណើរ ឲ្យនិករជនស្តាប់បដិបត្តិតាម ទាល់តែបរិសុទ្ធផុតទុក្ខភ័យដូចយ៉ាងព្រះអង្គ ហើយនាំពាក្យប្រដៅរបស់ព្រះអង្គតៗមក ជាប្រយោជន៍ដល់ប្រជុំជនជាច្រើនរហូតដល់សព្វថ្ងៃនេះ បើប្រសិនជាគ្មានព្រះសង្ឃជាអ្នកត្រង់ត្រាប់ ហើយបដិបត្តិនាំសាសនធម៌ប្រកាសតៗមកសោតទេ យើងរាល់គ្នាក្នុងជំនាន់នេះក៏នឹងល្ងិតល្ងង់ ឥតមានដឹងបាបបុណ្យគុណទោសអ្វី សុំលើកតួយ៉ាងក្នុងការដែលព្រះសង្ឃធ្វើប្រយោជន៍ដ៏ធំទុកឲ្យយើងរាល់គ្នា ឲ្យឃើញងាយៗ គឺកាលព្រះពុទ្ធអង្គទើបនឹងបរិនិព្វានហើយថ្មីៗ គណសង្ឃក្នុងតំណៀមមានព្រះមហាកស្សបត្ថេរជាប្រធាន បានប្រជុំគ្នាចាត់របៀបរៀបចំធម៌វិន័យដ៏ជាពុទ្ធវចនៈទុកជាពួកៗ ឲ្យដឹងចំនួនធម៌វិន័យមានប៉ុន្មាន ដើម្បីកុំឲ្យខ្ចាត់ខ្ចាយបាត់បង់ទៅ នឹងដើម្បីការពារកុំឲ្យពួកបាបជនអ្នកមានសន្តានទុច្ចរិតលាមក ក្លែងក្លាយសំដែងធម៌ប្លែងប្លម

ចូលមកលាយឡំក្នុងព្រះពុទ្ធសាសនា ព្រមទាំងសំដែងខុស វិគប្ប័យលក្ខណធម៌វិន័យទុកជាស្រេច ពួកយើងក្នុងជំនាន់ក្រោយទើបដឹងបានថា ព្រះពុទ្ធវចនៈមានប៉ុណ្ណេះ ប៉ុណ្ណោះគម្ពីរនឹងដឹងថា យ៉ាងនេះជាធម៌ជាវិន័យ យ៉ាងនេះមិនមែនធម៌ មិនមែនវិន័យពាក្យប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ, ក្រោយនោះមកគណសង្ឃបានប្រជុំគ្នាសង្គាយនា រៀបចំធម៌វិន័យ ២ ដងទៀតនៅក្នុងឥណ្ឌា តាមលំអានដែលព្រះថេរទាំងឡាយធ្វើមកហើយក្នុងកាលមុន ក្នុងគ្រាទី ៣ ព្រះមោគ្គលីបុត្តតិស្សត្ថេរជាសង្ឃនាយក បានបញ្ជូនព្រះថេរទាំងឡាយឲ្យទៅប្រកាសពុទ្ធសាសនាក្នុងនានាប្រទេស តាមដែលលោកកំណត់ទុកដល់ទៅ ៩ ប្រទេស ផ្សាយរហូតដល់មកប្រទេសកម្ពុជាយើងនេះ, លុះដល់ ព. ស. ៩០០ ឆ្នាយ ព្រះពុទ្ធឃោសត្ថេរនៅក្នុងឥណ្ឌា បានទៅលង្កាទ្វីបប្រែព្រះត្រៃបិដកអំពីភាសាសំស្ក្រឹតនឹងភាសាសីហឡ (លង្កា) មកជាភាសាមគធ បារដាក់ស្លឹករឹតទាល់តែចប់ទាំងអស់ វេលាក្រោយនោះមានព្រះសង្ឃខ្មែរនឹងព្រះសង្ឃប្រទេសឯទៀត បេញទៅរៀនព្រះត្រៃបិដកភាសាមគធ

នៅលង្កាហើយត្រឡប់មកនគរវិញ នាំយកទាំងព្រះត្រៃបិដក បែបនោះមកប្រដៅគ្នាក្នុងប្រទេស សឹងជាប់មានមកដល់សព្វថ្ងៃនេះ រាប់ថា ព្រះសង្ឃបានធ្វើប្រយោជន៍ជាបរហិតសម្បត្តិយ៉ាងធំដល់ប្រជុំជន នេះពោលតែប្រយោជន៍ខាងក្រៅដែលលោកធ្វើឲ្យដល់អ្នកដទៃ ។

បំណែកឯគុណប្រយោជន៍ខាងក្នុង ដែលលោកបំពេញសម្រាប់ខ្លួនលោកជាអត្តហិតសម្បត្តិនោះ គឺលោកសិក្សាត្រង់ត្រាប់ឱវាទរបស់ព្រះសម្មាសម្ពុទ្ធហើយ បដិបត្តិកាយវាចាចិត្ត ឲ្យស្អាតរាប ព្យាយាមលះគ្រឿងរឹតរួតចិត្តទុកក្នុងភព (សំយោជនៈ) ដោយលំដាប់ ទាល់តែបន្លះលោកុត្តរភូមិជាជាន់ៗឡើងទៅ មានថ្នាក់តាមដែលលះសំយោជនៈបានជា ៤ ជាន់ គឺជាន់ទី ១ លោកដែលតាំងនៅក្នុងសោតាបត្តិមគ្គនឹងសោតាបត្តិផល រួមហៅថា ព្រះសោតាបន្ន, ទី ២ លោកដែលតាំងនៅក្នុងសកិទាគាមិមគ្គនឹងសកិទាគាមិផល រួមហៅថា ព្រះសកិទាគាមី, ទី ៣ លោកដែលតាំងនៅក្នុងអនាគាមិមគ្គនឹងអនាគាមិផល រួមហៅថា ព្រះអនាគាមី, ទី ៤ លោកដែលតាំង

នៅក្នុងអរហត្តមគ្គនឹងអរហត្តផល រួមហៅថា ព្រះអរហន្ត ឬហៅថាព្រះខីណាស្រព, ដែលរាប់ថាជាព្រះសង្ឃសរណៈ ក្នុងទីនេះសំដៅយកព្រះសង្ឃ ៤ ពួកនេះ លោកជាអ្នកជំណាងអង្គសម្តេចព្រះបរមសាស្តា សូម្បីព្រះអង្គបរិនិព្វានទៅជាអង្វែងហើយ ពុទ្ធសាសនកាលកន្លងមកបាន ២៤៧០ ប្លាយឆ្នាំហើយ ព្រះពុទ្ធសាសនាក៏ស្ថិតនៅបរិបូណ៌ ដោយហេតុលោកយកចិត្តទុកដាក់ថែរក្សា នឹងទេសនាប្រដៅសិស្សានុសិស្សតមក រហូតមកដល់សម្មតិសង្ឃក៏ទទួលរាប់រងធ្វើតាមលំអាននោះតមកទៀត យើងរាល់គ្នាដែលកើតឡើងក្នុងជាន់ក្រោយ ទើបបានដឹងស្គាល់ព្រះពុទ្ធសាសនាដែលជាសាសនាឯកក្នុងលោក ជាសាសនាដែលត្រឹមត្រូវបំផុត ។

បំណែកឯគុណព្រះសង្ឃនោះលោកអាងក្នុងបទថា សុបដិបន្នោ លោកបដិបត្តិហើយល្អ, ឧជុបដិបន្នោ លោកបដិបត្តិហើយត្រង់ ញាយបដិបន្នោ លោកបដិបត្តិហើយដើម្បីដឹងពិត, សាមីចិបដិបន្នោ លោកបដិបត្តិហើយប្រពៃ ។ អាការដែលលោកបដិបត្តិល្អ បដិបត្តិត្រង់ បដិបត្តិដើម្បីដឹងពិត

បដិបត្តិប្រពៃ ទាំង ៤ ប្រការនេះប្រកាសព្រះសង្ឃគុណ អ្នកដែលបានតាមថាព្រះសង្ឃ គោរពទ្រង់នូវគុណសម្បត្តិយ៉ាងនេះ ព្រះសង្ឃសាវករបស់ព្រះដ៏មានព្រះភាគសុទ្ធតែជាអ្នកទ្រង់នូវអង្គគុណយ៉ាងនេះទាំងអស់ ដោយហេតុទាំងឡាយដែលពណ៌នាមក លោកទើបរាប់ព្រះសង្ឃថា ជាសរណៈប្រការ ១ ។

## វិធីដល់នូវព្រះត្រៃសរណគមន៍

ការដែលនឹងរាប់ថា ដល់នូវព្រះរតនត្រ័យជាសរណៈ មិនមែនគ្រាន់តែមាត់ថា ដល់ទទេ ៗ ហើយខ្លួនទៅធ្វើសេចក្ដីអាក្រក់ ឬនឹងអំពាវនាវឲ្យព្រះអង្គទៅជួយក្នុងការអាក្រក់ជាមួយខ្លួនផង យ៉ាងនេះមិនបាន ដូចយ៉ាងបុគ្គលដ៏ពួកខ្លះ វេលាកំលាំងកំហែងសតិបញ្ញានៅមានបរិបូណ៌មិនអំពល់នឹងព្រះ ទាល់តែវេលាឈឺធ្ងន់ទ្រមអន់កំលាំងកាយកំលាំងចិត្តហើយ ទើបមានមនុស្សចាំស្រែកដាក់ត្រចៀកថា ពុទ្ធោ អរហំ ៗ អ្នកជម្ងឺក៏ថាតាមទៅទាល់តែផុតខ្យល់ ជឿថាស្លាប់ហើយនឹងបានទៅកើតក្នុងទីល្អ ៗ មានឋានសួគ៌ជាដើម ដូច្នេះព្រះអរហំឯណានឹង

មកជួយត្រូវ មិនគោងមើលដទៃឆ្ងាយ សុំឲ្យមើលតែអ្នកស្រុកដែលនៅជិតខាង កាលយើងមិនដែលធ្វើល្អដល់គេសោះ លុះដល់យើងត្រូវភ័យអ្នកដទៃមកបៀតបៀន នឹងស្រែកអំពាវឲ្យគេមកជួយទាល់តែកក ក៏ស្ទើតមានអ្នកណាមកជួយ បើយើងធ្វើល្អដល់គេ មិនបាច់អំពាវក៏គេមកជួយឯង ដូចម្ដេចមិញព្រះក៏ដូច្នោះ កាលមិនបដិបត្តិតាមពាក្យប្រដៅរបស់ព្រះអង្គហើយ នឹងអំពាវឲ្យព្រះអង្គមកជួយម្ដេចត្រូវ ព្រោះព្រះអង្គមិនស្គាល់ ឬស្គាល់តែស្រពេចស្រពិល បើយើងរាប់អានព្រះអង្គដោយស្មោះត្រង់ ហើយឧស្សាហ៍បដិបត្តិតាមពាក្យប្រដៅរបស់ព្រះអង្គ ទាល់តែព្រះអង្គបាំបានជាក់ នោះមិនបាច់អំពាវរកក៏ព្រះអង្គមកជួយ ហើយមិនមែនជាទ្រង់ជួយតែក្នុងវេលាស្លាប់នោះទេ ទ្រង់បានជួយឲ្យបានសុខសម្រានរៀងរាប តាំងតែពីចាប់បដិបត្តិតាមពាក្យប្រដៅរបស់ព្រះអង្គមកហើយ ទៅខាងមុខក៏ទ្រង់ជួយឲ្យបានសេចក្ដីសុខទៀត តាមសមគួរនឹងយថាបដិបត្តិរបស់ខ្លួន ខនេះអ្នកបដិបត្តិអាចដឹងឃើញបានដោយខ្លួនឯង ។

បានពោលមកហើយថា សរណៈក្នុងព្រះពុទ្ធសាសនាមាន ៣ ប្រការ តែបើនឹងចាត់តាមថ្នាក់នៃគុណរបស់សរណៈនោះ តាមអាការដែលបុគ្គលបន្ទុះជា ២ យ៉ាង គឺលោកុត្តរសរណគមន៍ ១ លោកិយសរណគមន៍ ១ សរណគមន៍ដ៏ជាលោកុត្តរនោះ បាននឹងព្រះអរិយមគ្គញាណ របស់ព្រះអរិយដែលលោកបាន បន្ទុះដល់បឋមភូមិ គឺសោតាបត្តិមគ្គ រមែងផ្ដាច់បង់នូវឧបកិ-លេសនៃសរណគមន៍ មានសេចក្ដីសង្ស័យជាដើមឲ្យដាច់ជ្រះ ស្រឡះជាសមុច្ឆេទបហាន យឹតយកព្រះនិព្វានជាអារម្មណ៍ឲ្យ សម្រេចប្រយោជន៍ រាប់អានស្មោះក្នុងព្រះរតនត្រ័យជានិច្ច ឥតលំអៀងដោយកិច្ច សម្រេចតែក្នុងចិត្តមួយយ៉ាងប៉ុណ្ណោះ មិនបានប្រព្រឹត្តទៅក្នុងកាយវាចា ។

ចំណែកឯលោកិយសរណគមន៍នោះ បាននឹងសទ្ធាសេចក្ដី ជឿជាក់ក្នុងគុណព្រះរតនត្រ័យ និងបញ្ញាសេចក្ដីដឹងឃើញពិត ក្នុងគុណព្រះរតនត្រ័យ ព្រមដោយចេតនាដ៏ក្លាអាចបណ្ដាល ឲ្យបញ្ចេញនូវវិធីភេទសមាទាន មានពុទ្ធាទិគុណជាអារម្មណ៍ ឲ្យសំរេចកិច្ច តែអាចប្រែប្រួលបានក្នុងកាលឯណានីមួយ ។

គាថាធម្មបទ ប្រែ

របស់អាចារ្យ ហិម

ក្រុមជំនុំប្រែព្រះត្រៃបិដក

# ធម្មបទេ បឋមោ យមកវគ្គោ

---

ចក្ខុបាលត្ថេរវត្ថុ គាថា

(១) មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

មដ្ឋកុណ្ឌលីវត្ថុ គាថា

(២) មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

# យមកវគ្គ ទី ១ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងចក្ខុបាលត្ថេរ*

(១) ចេតសិកធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរដោយវិសេស សម្រេចហើយដោយចិត្ត ថាបើបុគ្គលឯណាមានចិត្ត គឺទោសប្រទុស្តហើយ នឹងពោលក្តី ធ្វើក្តី (គិតក្តី) នូវទុច្ចរិតទាំង ៣ ប្រការ ។ ផលជាទុក្ខតែងជាប់តាមបុគ្គលនោះព្រោះអំពើទុច្ចរិត ៣ ប្រការនោះឯង ដូចកង់ (រទេះ) ដែលវិលទៅតាមដានជើងគោ កាលកំពុងនាំទៅ (នូវនឹម ។

*គាថាក្នុងរឿងមាណពឈ្មោះមដ្ឋកុណ្ឌលី*

(២) ចេតសិកធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរដោយវិសេស សម្រេចហើយដោយចិត្ត ថាបើបុគ្គលឯណាមានចិត្តជ្រះថ្លាហើយ នឹងពោលក្តី ធ្វើក្តី (គិតក្តី) នូវអំពើសុចរិតទាំង ៣ ប្រការ ផលជាសុខតែងជាប់តាមបុគ្គលនោះព្រោះអំពើសុចរិត ៣ ប្រការនោះឯង ដូចស្រមោលដែលតែងអន្លោលតាមអត្តភាព ។

## ធម្មបទេ បឋមោ យមកវគ្គោ

### តិស្សត្ថេរវត្ថុគាថា

(៣) អកោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ

យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ

អកោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ

យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

### កាឡីយក្ខិនីវត្ថុគាថា

(៤) ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

## យមកវគ្គទី ១ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងព្រះតិស្សត្ថេរ*

(៣) ពួកជនណា ចងសេចក្ដីក្រោធនោះទុកដោយគិតថា អ្នកឯណោះជេរអញ អ្នកឯណោះវាយអញ អ្នកឯណោះផ្ចាញ់អញ អ្នកឯណោះលួចយកនូវទ្រព្យរបស់អញ ពៀររបស់ជនទាំងនោះមិនស្ងប់រម្ងាប់បានឡើយ ។

លុះតែពួកជនណា មិនចងសេចក្ដីក្រោធនោះទុកដោយគិតថា អ្នកឯណោះជេរអញ អ្នកឯណោះវាយអញ អ្នកឯណោះផ្ចាញ់អញ អ្នកឯណោះលួចយកនូវទ្រព្យរបស់អញ ( ដូច្នេះទើប ) ពៀររបស់ជនទាំងនោះ ស្ងប់រម្ងាប់ទៅបាន ។

*គាថាក្នុងរឿងនាងយក្ខិនីឈ្មោះកាលី*

(៤) ពៀរទាំងឡាយក្នុងលោកនេះ មិនដែលស្ងប់រម្ងាប់ដោយការចងពៀរបានម្ដងឡើយ ពៀរនឹងស្ងប់រម្ងាប់ដោយការមិនចងពៀរ ធម៌មិនធ្វើពៀរតបពៀរ នេះជាធម៌របស់ព្រះខីណាស្រពមានព្រះពុទ្ធជាម្ចាស់ជាដើម ( លោកតែងប្រព្រឹត្តឱ្យស្ងប់រម្ងាប់ពៀរ ) ក្នុងកាលមុន ។

# ធម្មបទេ បឋមោ យមកវគ្គោ

## កោសម្ពិកវត្ថុគាថា

(៥) បរេ ច ន វិជានន្តិ មយមេត្ថ យមាមសេ[១]

យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា

## មហាកាឡត្ថេរវត្ថុគាថា

(៦) សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ

ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ

តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្ពលំ ។

---

១ ម. យមាមសេ ។

## យមកវគ្គទី ១ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងកោសម្ពិកភិក្ខុ*

(៥) ជនទាំងឡាយដទៃរមែងមិនដឹងច្បាស់ នូវជម្លោះដូច្នេះថា យើងទាំងឡាយនឹងវិនាសក្នុងកណ្ដាលជំនុំសង្ឃនេះ បណ្ដាជនទាំងនោះ ជនទាំងឡាយឯណា ដឹងច្បាស់ (នូវជម្លោះដូច្នេះ) មេធគធមិ គឺជម្លោះប្រកែកទាំងឡាយ តែងស្ងប់រម្ងាប់អំពីសំណាក់នៃជនទាំងនោះ ។

*គាថាក្នុងរឿងព្រះថេរឈ្មោះមហាកាឡ*

(៦) កិលេសមារតែងគ្របសង្កត់ នូវបុគ្គលដែលមានកិរិយាឃើញរឿយ ៗ នូវអារម្មណ៍ថាល្អជាប្រក្រតី មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ជាបុគ្គលខ្ជិលច្រអូស (គឺលុះក្នុងអំណាចនៃអកុសលវិតក្ក) មានព្យាយាមថយថោក (នោះឯង) ដូចខ្យល់តែងគ្របសង្កត់ នូវដើមឈើដែលមានកម្លាំងថយ ។

## ធម្មបទេ បឋមោ យមកវគ្គោ

អសុភានុបស្សឹ វិហរន្តំ    ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ    សទ្ធំ អារទ្ធវីរិយំ
តំ វេ នប្បសហតី មារោ    វាតោ សេលំ វ បព្វតំ ។

### ទេវទត្តវត្ថុគាថា

(៣) អនិក្កសាវោ កាសាវំ    យោ វត្ថំ បរិទហេស្សតិ
អបេតោ ទមសច្ចេន    ន សោ កាសាវ មរហតិ ។
យោ ច វន្តកសាវស្ស    សីលេសុ សុសមាហិតោ
ឧបេតោ ទមសច្ចេន    ស វេ កាសាវមរហតិ ។

យមកវគ្គទី ១ ក្នុងព្រះធម្មបទ

កិលេសមារ តែងគ្របសង្កត់មិនបាន នូវបុគ្គលដែលមានកិរិយាឃើញរឿយៗ នូវអារម្មណ៍ថា មិនល្អមិនស្អាតជាប្រក្រតី សង្រួមដោយប្រពៃ ក្នុងឥន្ទ្រិយទាំងឡាយផង ដឹងប្រមាណក្នុងភោជនផង មានសទ្ធា (ជំមាំ) ផង មានព្យាយាមប្រារព្ធហើយផង (នោះឯង) ដូចខ្យល់គ្របសង្កត់ នូវថ្មភ្នំមិនកក្រើកញាប់ញ័រឡើយ ។

គាថាក្នុងរឿងព្រះថេរឈ្មោះទេវទត្ត

(៧) បុគ្គលឯណា មានទឹកមានរសបត់គឺរាគាទិក្កិលេសមិនទាន់ប្រាសចេញហើយ ជាបុគ្គលប្រាសចាកកិរិយាទូន្មាននូវឥន្ទ្រិយនឹងវចីសច្ច នឹងស្លៀកដណ្ដប់នូវសំពត់កាសាវពស្ត្រ គឺសំពត់ដែលគេជ្រលក់ដោយទឹកអម្ចត់ បុគ្គលនោះមិនគួរដើម្បីនឹងស្លៀកដណ្ដប់ នូវសំពត់កាសាវពស្ត្រ (នោះទេ) ។

លុះតែបុគ្គលឯណាមួយ មានទឹកអម្ចត់គឺរាគាទិក្កិលេសខ្ជាក់ចោលស្រឡះហើយ ជាបុគ្គលមានចិត្តដំកល់មាំក្នុងសីលទាំងឡាយ ប្រកបដោយកិរិយាទូន្មាននូវឥន្ទ្រិយនឹងវចីសច្ច បុគ្គលនោះឯង ទើបគួរដើម្បីនឹងស្លៀកដណ្ដប់នូវសំពត់កាសាវពស្ត្រ (នោះពិត) ។

## ធម្មបទេ បឋមោ យមកវគ្គោ

### សញ្ជយវត្ថុគាថា

(៨) អសារេ សារមតិនោ សារេ ចាសារទស្សិនោ
តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។
សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ
តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។

### នន្ទត្ថេរវត្ថុគាថា

(៩) យថា អគារំ ទុច្ឆន្នំ វុដ្ឋី សមតិវិជ្ឈតិ
ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។

## យមកវគ្គទី ១ ក្នុងព្រះធម្មបទ

### គាថាក្នុងរឿងគ្រូឈ្មោះសញ្ជយ

(៨) ជនទាំងឡាយឯណា ដឹងថា មានខ្លឹមក្នុងធម៌ដែលគ្មានខ្លឹមផង យល់ឃើញថា គ្មានខ្លឹមក្នុងធម៌ដែលមានខ្លឹមផង ជនទាំងឡាយនោះឈ្មោះថា មានដម្រិះខុសជាអារម្មណ៍ មិនដែលត្រាស់ដឹងនូវធម៌ដែលមានខ្លឹមនោះបានឡើយ ។

ជនទាំងឡាយឯណា ដឹងនូវធម៌ដែលមានខ្លឹមថាជាធម៌គ្មានខ្លឹមផង ដឹងនូវធម៌ដែលគ្មានខ្លឹម ថាជាធម៌គ្មានខ្លឹមផង ជនទាំងឡាយនោះឈ្មោះថា មានដម្រិះត្រូវជាអារម្មណ៍ តែងត្រាស់ដឹងនូវធម៌ដែលមានខ្លឹមនោះបាន ។

### គាថាក្នុងរឿងព្រះថេរឈ្មោះនន្ទ

(៩) ដំណក់ភ្លៀងលេចរហូត នូវផ្ទះមានដម្បូលផ្ទះ មានឧបមាយ៉ាងណា រាគៈគឺដម្រេកតែងចាក់ធ្លុះរហូត នូវចិត្តដែលបុគ្គលមិនបានភាវនាហើយ មានឧបមេយ្យយ៉ាងនោះឯង ។

## ធម្មបទេ បឋមោ យមកវគ្គោ

យថា អគារំ សុច្ឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ

ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។

ចុន្ទសូករិកវត្ថុគាថា

(១០) ឥធ សោចតិ បេច្ច សោចតិ បាបការី ឧភយត្ថ សោចតិ

សោ សោចតិ សោ វិហញ្ញតិ ទិស្វា កម្មកិលិដ្ឋមត្តនោ ។

ធម្មិកឧបាសកវត្ថុគាថា

(១១) ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ

សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។

## យមកវគ្គទី ១ ក្នុងព្រះធម្មបទ

ដំណក់ភ្លៀងមិនបានលេចរហូត នូវផ្ទះមានដម្បូលគត់ មានឧបមាយ៉ាងណា រាគៈគឺដម្រេក មិនជ្រាបជ្រាប់បាក់ធ្លុះ នូវចិត្ត ដែលបុគ្គលបានភាវនាហើយ ដោយសមថភាវនានឹង វិបស្សនាភាវនា មានឧបមេយ្យយ៉ាងនោះឯង ។

*គាថាក្នុងរឿងបុរសឈ្មោះចុន្ទសូករិក*

(១០)បុគ្គលមានប្រក្រតីធ្វើបាប រមែងសោយសោកក្នុងលោក ទាំងពីរ គឺសោយសោកក្នុងលោកនេះ នឹងសោយសោកក្នុង លោកខាងនាយ បុគ្គលធ្វើបាបនោះរមែងសោយសោក រមែង លំបាកក្តៅក្រហាយ ព្រោះឃើញនូវអំពើសៅហ្មងរបស់ខ្លួន ។

*គាថាក្នុងរឿងឧបាសកឈ្មោះធម្មិក*

(១១)បុគ្គលអ្នកធ្វើបុណ្យ តែងរីករាយក្នុងលោកទាំងពីរ គឺរីក រាយក្នុងលោកនេះ នឹងរីករាយក្នុងលោកខាងនាយ បុគ្គលអ្នក ធ្វើបុណ្យនោះតែងរីករាយ (ក្នុងលោកនេះអំពីមុនធ្វើមរណកាល) ព្រោះឃើញនូវអំពើដ៏ស្អាតបរិសុទ្ធរបស់ខ្លួន លុះធ្វើមរណកាល រួចហើយទើបរីករាយដ៏ក្រៃលែង (ក្នុងលោកខាងនាយទៀត) ។

## ធម្មបទេ បឋមោ យមកវគ្គោ

ទេវទត្តវត្ថុគាថា

(១២) ឥធ តប្បតិ បេច្ច តប្បតិ បាបការី ឧភយត្ថ តប្បតិ
បាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។

សុមនទេវីវត្ថុគាថា

(១៣) ឥធ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ
បុញ្ញំ មេ កតន្តិ នន្ទតិ ភិយ្យោ នន្ទតិ សុគតឹ គតោ ។

ទ្វេសហាយកភិក្ខុវត្ថុគាថា

(១៤) ពហុម្បិ ចេ សហិតំ ភាសមានោ
ន តក្ករោ ហោតិ នរោ បមត្តោ

## យមកវគ្គ ទី ១ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងភិក្ខុឈ្មោះទេវទត្ត*

(១២) បុគ្គលអ្នកធ្វើបាប រមែង (ទោមនស្ស) ក្ដៅក្រហាយក្នុងលោកទាំងពីរ គឺក្ដៅក្រហាយក្នុងលោកនេះ ដោយគិតថា អំពើបាបអាត្មាអញបានធ្វើហើយជួប្រេះ ១ (លុះធ្វើមរណកាល) ទៅកាន់ទុគ្គតិ ក៏ក្ដៅក្រហាយជាក្រៃលែងទៀតជួប្រេះ ១ ។

*គាថាក្នុងរឿងនាងសុមនទេវី*

(១៣) បុគ្គលអ្នកធ្វើបុណ្យ តែង (សោមនស្ស) ត្រេកអរក្នុងលោកទាំងពីរ គឺត្រេកអរក្នុងលោកនេះ ដោយគិតថា បុណ្យអាត្មាអញបានធ្វើហើយជួប្រេះ ១ (លុះធ្វើមរណកាល) ទៅកាន់សុគតិ ក៏ត្រេកអរដ៏ក្រៃលែងទៀតជួប្រេះ ១ ។

*គាថាក្នុងរឿងភិក្ខុពីររូបជាសំឡាញ់គ្នា*

(១៤) ថាបើជន (ឯណា) ពោលឬបង្រៀនពុទ្ធវិបនសម្បីមានប្រមាណច្រើន (ដល់អ្នកដទៃ) តែថាមិនធ្វើតាមពុទ្ធវិបននោះឡើយ ត្រឡប់ទៅជាបុគ្គលប្រមាទវិញ ជននោះ

គោបោវ គាវោ គណយំ បរេសំ

ន ភាគវា សាមញ្ញស្ស ហោតិ ។

អប្បម្បិ ចេ សហិតំ ភាសមានោ

ធម្មស្ស ហោតិ អនុធម្មចារី

រាគញ្ច ទោសញ្ច បហាយ មោហំ

សម្មប្បជានោ សុវិមុត្តចិត្តោ ។

អនុបាទិយានោ ឥធ វា ហុរំ វា

ស ភាគវា សាមញ្ញស្ស ហោតិ ។

យមកវគ្គោ បឋមោ វគ្គោ សមត្តោ ។

គ្មានបានចំណែកនៃសាមញ្ញផល គឺរសជាតិធម៌ក្នុងព្រះពុទ្ធសាសនាឡើយ (បានចំណែកតែដោយការធ្វើនូវវត្តប្រតិបត្តិអំពីសំណាក់នៃកូនសិស្សតែប៉ុណ្ណោះ) ដូចនាយគោបាលកាលស៊ីឈ្នួលឃ្វាលគោឲ្យអ្នកដទៃ (មិនបានបរិភោគបញ្ចគោរសឡើយ) បានតែថ្លៃឈ្នួលប៉ុណ្ណោះឯង ។

ថាបើជនឯណាពោលឬបង្រៀនពុទ្ធវចន សូម្បីបន្តិចបន្តួចតែជាប្រព្រឹត្តនូវធម៌ គឺបុព្វភាគបដិបទាមានបតុបារិសុទ្ធិសីលជាដើមដ៏សមគួរដល់នវលោកុត្តរធម៌ បានលះបង់នូវរាគផងទោសផង មោហផង កំណត់ដឹងនូវធម៌ (ដែលខនគួរកំណត់ដឹង) មានចិត្តរួចស្រឡះហើយ (ដោយអំណាចនៃវិមុត្តិមានតទង្គវិមុត្តិជាដើម) ។ គ្មានសេចក្ដីប្រកាន់មាំ (នូវខន្ធអាយតននឹងធាតុខាងក្នុងខាងក្រៅ) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ជននោះឈ្មោះថា ជាអ្នកមានចំណែកនៃសាមញ្ញគឺមគ្គនឹងផលបាន ។

យមកវគ្គ ទីបឋម ចប់ ។

# ធម្មបទេ ទុតិយោ អប្បមាទវគ្គោ

## សាមាវតីវត្ថុ គាថា

(១) អប្បមាទោ អមតំ បទំ    បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ    យេ បមត្តា យថា មតា ។
ឯតំ[១] វិសេសតោ ញត្វា    អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ    អរិយានំ គោចរេ រតា ។

## សាមាវតីវត្ថុ គាថា

តេ ឈាយិនោ សាតតិកា    និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ    យោគក្ខេមំ អនុត្តរំ ។

---
១ ម. ឯវំ ។

## អប្បមាទវគ្គទី ២ ក្នុងព្រះធម្មបទ

គាថាគន្ថរឿងនាងសាមាវតី

(១) សេចក្ដីមិនប្រមាទជាផ្លូវនៃព្រះនិព្វានឈ្មោះថាអមត គឺមិនស្លាប់ សេចក្ដីប្រមាទជាផ្លូវនៃសេចក្ដីស្លាប់ ជនទាំងឡាយ (ឯណា) មិនប្រមាទ (ជនទាំងឡាយនោះ) សូម្បីស្លាប់ហើយក៏ឈ្មោះថាមិនស្លាប់ឡើយ (ជនទាំងឡាយឯណា) ប្រមាទហើយ (ជនទាំងឡាយនោះ) សូម្បីរស់នៅឡើយ ក៏ទុកដូចជាស្លាប់ហើយ ។ ពួកបណ្ឌិតអ្នកមានប្រាជ្ញា ដឹងច្បាស់នូវហេតុដ៏ប្លែកគ្នានេះហើយ ស្ថិតនៅក្នុងសេចក្ដីមិនប្រមាទ រីករាយក្នុងសេចក្ដីមិនប្រមាទ ត្រេកអរពេញចិត្តតែក្នុងធម៌ជាអារម្មណ៍នៃព្រះអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើម ។

គាថាគន្ថរឿងនាងសាមាវតី

បណ្ឌិតទាំងឡាយនោះ មានប្រក្រតីដុតបំផ្លាញនូវកិលេសចោលបង់ មានព្យាយាមប្រកបដោយកាយនឹងចិត្តរឿយ ៗ មានសេចក្ដីប្រឹងប្រែងដ៏មាំមួនអស់កាលជានិច្ច តែងបាននូវព្រះនិព្វានជាទីក្សេមចាកកិលេស ជាទីប្រកបសត្វឲ្យលិចចុះក្នុងវដ្ដទុក្ខ ឥតមានគុណជាតដទៃក្រៃលែងជាងឡើយ ។

# ធម្មបទេ ទុតិយោ អប្បមាទវគ្គោ

កុម្ភឃោសកវត្ថុ គាថា

(២) ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ

សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។

ចូឡបន្ថកវត្ថុ គាថា

(៣) ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច

ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។

# អប្បមាទវគ្គទី ២ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងកុម្ភឃោសក*

(២) កេរ្តិ៍ឈ្មោះយសសក្តិជាដើម តែងចំរើនដល់បុគ្គលដែលមានព្យាយាមប្រឹងប្រែង មានស្មារតីបរិបូណ៌ មានការងារដ៏ស្អាត មិនមានទោស មានប្រក្រតីពិចារណាហើយជាមុនទើបធ្វើអ្វី ៗ នីមួយ សង្រួមដោយកាយទ្វារជាដើមមិនឲ្យមានបន្លោះ រកស៊ីចិញ្ចឹមជីវិតប្រកបដោយគន្លងធម៌ មិនមានសេចក្តីប្រមាទ គឺមិនប្រាសចាកស្មារតីឡើយ ។

*គាថាក្នុងរឿងចូឡបន្ថក*

(៣) អន្លង់គឺកិលេសគ្របសង្កត់មិនបាន នូវកោះគឺអរហត្តផលឯណា អ្នកប្រាជ្ញគប្បីធ្វើនូវកោះគឺអរហត្តផល (នោះ) ឲ្យជាទីពឹងរបស់ខ្លួន ដោយសេចក្តីព្យាយាម ១ ដោយសេចក្តីមិនប្រហែសធ្វេសស្មារតី ១ ដោយកិរិយាសង្រួមក្នុងចតុបារិសុទ្ធិសីល ១ ដោយកិរិយាទូន្មាននូវឥន្ទ្រិយទាំងប្រាំមួយ ១ ។

# ធម្មបទេ ទុតិយោ អប្បមាទវគ្គោ

## ពាលនក្ខត្តឃុដ្ឋគាថា

(៤) បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា

អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំ វ រក្ខតិ ។

មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ

អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។

## អប្បមាទវគ្គទី ២ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងពាលនក្ខត្ត*

(៤) ពួកជនដែលល្ងង់អប្បឥតប្រាជ្ញា មិនដឹងនូវប្រយោជន៍ក្នុងឥធលោកនិងប្រយោជន៍ក្នុងបរលោក តែងប្រកបរឿយ ៗ នូវសេចក្ដីប្រមាទ ចំណែកឯអ្នកប្រាជ្ញលោកដឹង (នូវប្រយោជន៍ទាំងពីរនោះហើយ) តែងរក្សានូវសេចក្ដីមិនប្រមាទ ដូចបុគ្គលរក្សានូវទ្រព្យដ៏ប្រសើរថ្លៃថ្លាដូច្នោះឯង ព្រោះហេតុដូច្នោះ អ្នកទាំងឡាយចូរកុំប្រកបរឿយ ៗ នូវសេចក្ដីប្រមាទឡើយ ចូរកុំប្រកបរឿយ ៗ នូវសេចក្ដីត្រេកអរនឹងសេចក្ដីស្និទ្ធស្នាល (ក្នុងកិលេសកាមវត្ថុកាម) ឡើយ ព្រោះបុគ្គលដែលមិនប្រមាទបានដុតបំផ្លាញ នូវកិលេសហោលបង់ហើយ តែងដល់នូវសេចក្ដីសុខ (ក្នុងព្រះនិព្វាន) ដ៏ទូលាយ ។

# ធម្មបទេ ទុតិយោ អប្បមាទវគ្គោ

មហាកស្សបត្ថេរវត្ថុគាថា

(៨) បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ

បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនំ បជំ ។

បព្វតដ្ឋោវ ភូមដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។

# អប្បមាទវគ្គទី ២ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងព្រះថេរឈ្មោះកស្សប*

(៨) បណ្ឌិតអ្នកមានប្រាជ្ញាជាគ្រឿងទ្រង់ លោកតែងបន្ទោបង់នូវសេចក្ដីប្រមាទ ដោយសេចក្ដីមិនប្រមាទបាន ក្នុងកាលណាហើយ (ក្នុងកាលណោះ) លោកក៏ឡើងកាន់ប្រាសាទគឺបញ្ញា (ដោយដំណើរគឺបដិបទា) ជាបុគ្គលមិនមានសេចក្ដីសោក កាលនឹងក្រឡេកមើលពពួកនៃសត្វដែលមានសេចក្ដីសោក តែងមើលឃើញនូវជនពាលល្ងង់ (កំពុងតែចុតិខ្លះកំពុងកើតខ្លះ) ដោយទិព្វចក្ខុបានដោយងាយ ដូចបុគ្គលស្ថិតនៅលើកំពូលភ្នំ ហើយក្រឡេកមើលសត្វដែលស្ថិតនៅលើផែនដីបានដោយងាយដូច្នោះឯង ។

# ធម្មបទេ ទុតិយោ អប្បមាទវគ្គោ

### ទ្វេសហាយកភិក្ខុវត្ថុគាថា

(៦) អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ

អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។

### សក្កវត្ថុគាថា

(៧) អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ

អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។

## អប្បមាទវគ្គទី ២ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងទេសហាយកក្កិត្ត*

(៦) អ្នកប្រាជ្ញដែលមានប្រាជ្ញាដ៏ខ្ពង់ខ្ពស់ កាលបើបុគ្គលទាំងឡាយប្រមាទប្រហែសធ្វេសដេកលក់ហើយ លោកតែងជាអ្នកបរិបូណ៌ដោយសេចក្ដីមិនប្រមាទ មានព្យាយាមជាគ្រឿងភ្ញាក់រឭកដ៏ច្រើន ក៏បោះបង់ចោលនូវបុគ្គលដែលមានប្រាជ្ញាទន់ទាប (ដោយបរិយត្តិធម៌នឹងអធិគមធម៌) ហើយត្រេចទៅដូចជាសេះសិន្ធវៈមានសន្ទុះដ៏រហ័ស បោះបង់ចោលនូវសេះដ៏មានកម្លាំងទន់ទាបយឺតយូរ ដូច្នោះឯង ។

*គាថាក្នុងរឿងសក្ក*

(៧) មឃមាណពគឺព្រះឥន្ទ្រ បានដល់នូវភាវនៃខ្លួនដ៏ប្រសើរដោយវិសេស ជាងទេវតាទាំងឡាយ (ដែលស្ថិតនៅក្នុងទេវលោកទាំងពីរជាន់) ព្រោះតែសេចក្ដីមិនប្រមាទ (អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម) តែងសរសើរនូវសេចក្ដីមិនប្រមាទ; ឯសេចក្ដីប្រមាទលោកតែងតិះតិះដៀលសព្វកាលសព្វវេលា ។

# ធម្មបទេ ទុតិយោ អប្បមាទវគ្គោ

អញ្ញតរភិក្ខុវត្ថុគាថា

(៨) អប្បមាទរតោ ភិក្ខុ   បមាទេ ភយទស្សិ វា

សញ្ញោជនំ អនុំថូលំ   ឌហំ អគ្គីវ គច្ឆតិ ។

និគមវាសិតិស្សត្ថេរវត្ថុគាថា

(៩) អប្បមាទរតោ ភិក្ខុ   បមាទេ ភយទស្សិ វា

អភព្វោ បរិហានាយ   និព្វានស្សេវ សន្តិកេ ។

អប្បមាទវគ្គោ ទុតិយោ សមត្តោ ។

# អប្បមាទវគ្គទី ២ ក្នុងព្រះធម្មបទ

គាថាក្នុងរឿងអញ្ញតរភិក្ខុ

(៨) ភិក្ខុត្រេកអរក្នុងសេចក្ដីមិនប្រមាទផង មានប្រក្រតីឃើញនូវភ័យក្នុងសេចក្ដីប្រមាទផង ដុតនូវសញ្ញោជនៈដែលជាធម៌តែងប្រកបនូវសត្វទុកក្នុងសង្សារវដ្ដទាំងតូចទាំងធំបេញ (ដោយភ្លើងគឺមគ្គញាណ) ដូចភ្លើងដែលឆេះនូវប្រឆេះរកាប់តូចនឹងធំ ទើបទៅកាន់ព្រះនិព្វានបាន ដូច្នោះឯង ។

គាថាក្នុងរឿងនិគមវាសីតិស្សត្ថេរ

(៩) ភិក្ខុអ្នកត្រេកអរក្នុងសេចក្ដីមិនប្រមាទផង អ្នកឃើញភ័យក្នុងសេចក្ដីប្រមាទផង មិនគួរនឹងសាបសូន្យ (ចាកសមថធម៌និងវិបស្សនាធម៌ឬមគ្គនិងផលឡើយ) គង់តែនឹងស្ថិតនៅក្នុងសំណាក់ព្រះនិព្វានមិនខាន ។

អប្បមាទវគ្គទី ២ ចប់ ។

## ធម្មបទេ តតិយោ ចិត្តវគ្គោ

មេឃិយត្ថេរវត្ថុគាថា

(១) ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ
ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ
វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ
បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។

អញ្ញតរភិក្ខុវត្ថុគាថា

(២) ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ
ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។

## ចិត្តវគ្គទី ៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងមេឃិយត្ថេរ*

(១)អ្នកមានប្រាជ្ញាតែងធ្វើចិត្តដែលញាប់ញ័រឃ្លេងឃ្លោងរក្សាបានដោយកម្រឲ្យជាចិត្តត្រង់បាន ដូចជាងព្រួញពត់ព្រួញឲ្យត្រង់ដូច្នោះឯង ចិត្តនេះឯងដែលបុគ្គលលើកឡើងហើយចាកអាល័យគឺកាមគុណ បោះទៅលើគោកពោលគឺវិបស្សនាកម្មដ្ឋាន ដើម្បីនឹងលះបង់នូវវិស័យនៃមារ ក៏តែងញាប់ញ័រដូចជាត្រីដែលព្រានត្រីចាប់លើកឡើងចាកទីនៅគឺទឹក បោះទៅលើគោក តែងញាប់ញ័រដូច្នោះឯង ។

*គាថាក្នុងរឿងអញ្ញតរភិក្ខុ*

(២) សេចក្តីទូន្មាននូវចិត្តដ៏ស្រាលដែលគេឃ្មញ់ឃ្លាល់បានដោយកម្រ មានប្រក្រតីលង់ពុះទៅក្នុងអារម្មណ៍ណាមួយបានហើយ តែងជាគុណញុាំងប្រយោជន៍ឲ្យសម្រេច ចិត្តដែលគេបង្ហឹកបានហើយនោះ តែងនាំនូវសេចក្តីសុខមកឲ្យ ។

# ធម្មបទេ តតិយោ ចិត្តវគ្គោ

### ឧក្កណ្ឋិតភិក្ខុវត្ថុគាថា

(៣) សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

### ភាគិនេយ្យសង្ឃរក្ខិតត្ថេរវត្ថុគាថា

(៤) ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ
យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។

### ចិត្តហត្ថត្ថេរវត្ថុគាថា

(៥) អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ
បរិប្លវបសាទស្ស បញ្ញា ន បរិបូរតិ ។
អនវស្សុតចិត្តស្ស អនន្វាហតចេតសោ
បុញ្ញបាបបហីនស្ស នត្ថិ ជាគរតោ ភយំ ។

# ចិត្តវគ្គទី ៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងទុក្កណ្ឌិតភិក្ខុ*

(៣) អ្នកមានប្រាជ្ញាគួររក្សាចិត្តដែលគេឃើញបានដោយកម្រក្រៃពេក ដែលល្អិតក្រៃពេក ដែលមានប្រក្រតីធ្លាក់ចុះទៅក្នុងអារម្មណ៍ណាមួយឡើបាន ចិត្តដែលគេរក្សាបានហើយនោះតែងនាំយកនូវសេចក្ដីសុខមកឲ្យមិនខានឡើយ ។

*គាថាក្នុងរឿងភាគិនេយ្យសង្ឃរក្ខិត*

(៤) ជនទាំងឡាយឯណាសង្រួមនូវចិត្ត ដែលមិនមានសរីរ ដែលត្រេចទៅតែម្នាក់ឯង តែងទទួលនូវអារម្មណ៍ក្នុងទីឆ្ងាយ មានគុហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ បាន ជនទាំងនោះនឹងផុតចាកបំណងនៃមារមិនខានឡើយ ។

*គាថាក្នុងរឿងចិត្តហត្ថត្ថេរ*

(៥) បុគ្គលដែលមានចិត្តមិនអាំម្ចូន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្ដីជ្រះថ្លាអណ្ដែតឡើង មិនដែលមានបញ្ញាបរិបូណ៌ទេ ។ បុគ្គលដែលមានចិត្តមិនប្រឡាក់ដោយរាគៈ មានចិត្តដែលទោសៈមិនខ្ទាំងខ្ទប់ មានបុណ្យនិងបាបបន្សាត់បង់ហើយ ជាអ្នកភ្ញាក់រឭកឿយៗ បុគ្គលនោះគ្មានភ័យឡើយ ។

## ធម្មបទេ តតិយោ ចិត្តវគ្គោ

អារទ្ធវិបស្សកភិក្ខុវត្ថុគាថា

(៦) កុម្ភូបមំ កាយមិមំ វិទិត្វា នគរូបមំ ចិត្តមិទំ ឋបេត្វា

យោធេថ មារំ បញ្ញាវុធេន ជិតញ្ច រក្ខេ អនិវេសនោ សិយា ។

បូតិគត្តតិស្សត្ថេរវត្ថុគាថា

(៧) អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ

ឆុឌ្ឌោ[១] អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។

---

១ ម. ឆុទ្ធោ ។

# ចិត្តវគ្គ ទី ៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងភិក្ខុវិបស្សកភិក្ខុ*

(៦) បុគ្គលកាលបើដឹងច្បាស់នូវកាយនេះថា ដូចឆ្នាំង ហើយគប្បីបិទឃាត់ចិត្តនេះ ឲ្យដូចជាបិទទ្វារនៃនគរ គប្បីផ្ចាញ់នូវមារដោយអាវុធគឺបញ្ញា គប្បីរក្សាទុក (នូវធម៌) ដែលខ្លួនស្វែងរកបានថ្មីៗ កុំឲ្យវិនាសបង់ឡើយ ហើយគប្បីជាបុគ្គលមិនមានលំនៅ ។

*គាថាក្នុងរឿងបូតិគត្តតិស្សត្ថេរ*

(៣) ឱហ្ន៎កាយនៃយើងនេះមិនយូរឡើយ ទាត់ស្តិតស្មេរឡើយ តែវិញ្ញាណទៅប្រាសហើយ នៅតែកាយទទេ នឹងដេកសង្កត់លើផែនដី ដូចជាអង្កត់ឧស សោះសូន្យឥតមានប្រយោជន៍ឡើយ ។

# ធម្មបទេ តតិយោ ចិត្តវគ្គោ

នន្ទគោបាលត្ថេរវត្ថុគាថា

(៨) ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ
មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ ។

សោរេយ្យត្ថេរវត្ថុគាថា

(៩) ន តំ មាតាបិតា កយិរា អញ្ញេ វា[1] បន ញាតកា
សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ។

ចិត្តវគ្គោ តតិយោ សមត្តោ ។

---

១ ម. វាបិ ច ។

## ចិត្តវគ្គទី ៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងនន្ទគោបាលក*

(៨) ចោរឃើញនូវចោរដូចគ្នា (ដែលជាសត្រូវដល់គ្នានឹងគ្នាហើយ) ក៏ធ្វើសេចក្ដីវិនាសឯណាដល់គ្នាមិនខាន ពុំនោះសោតបុគ្គលមានពៀរ ឃើញនូវបុគ្គលមានពៀរដូចគ្នាដែលបានចងទុកមកហើយ ក៏ធ្វើសេចក្ដីវិនាសឯណាដល់គ្នាមិនខាន ក៏ឯចិត្តដែលបុគ្គលដំកល់ទុកខុសហើយ នឹងធ្វើនូវបុគ្គលនោះឲ្យជាបុគ្គលលាមកអាក្រក់ក្រៃលែង ជាងសេចក្ដីវិនាសដែលចោរ ឬបុគ្គលមានពៀរធ្វើដល់គ្នានោះឯង ។

*គាថាក្នុងរឿងសោរេយ្យ*

(៩) មាតាបិតាក្ដីក៏ធ្វើហេតុនោះមិនបាន ពុំនោះសោតជនទាំងឡាយដទៃដែលជាញាតក្ដី ក៏ធ្វើនូវហេតុនោះមិនបាន ចិត្តដែលបុគ្គលដំកល់ទុកត្រូវ ក្នុងកុសលកម្មបថទេតើ ធ្វើនូវបុគ្គលនោះឲ្យប្រសើរលើសលុបជាងហេតុនោះបាន ។

ចិត្តវគ្គទី ៣ ចប់ ។

# ធម្មបទេ ចតុត្ថោ បុប្ផវគ្គោ

## បញ្ចសតភិក្ខុវត្ថុគាថា

(១) កោ ឥមំ បឋវឹ វិចេស្សតិ[១] យមលោកញ្ច ឥមំ សទេវកំ

កោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ។

សេខោ បឋវឹ វិចេស្សតិ យមលោកញ្ច ឥមំ សទេវកំ

សេខោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ។

---

១ វិជេស្សតីតិបិ បាឋោ ។

## បុប្ផវគ្គទី ៤ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿនបញ្ចសតភិក្ខុ*

(១) អ្នកណាពិចារណាឃើញច្បាស់នូវផែនដីគឺអត្តភាពនេះផង នូវអបាយលោកទាំង ៤ ផង នូវមនុស្សលោកនេះព្រមទាំងទេវលោកផង, អ្នកណានឹងពិចារណាឃើញច្បាស់នូវបំណែកនៃធម៌ គឺពោធិបក្ខិយធម៌ទាំង ៣៧ ដែលព្រះតថាគតសំដែងដោយប្រពៃ ដូចជាជាងក្រងផ្កាដែលឈ្លាសវាងវៃជ្រើសរើសនូវផ្កានោះ ។ ព្រះសេខបុគ្គល ៧ ពួកលោកអាចនឹងពិចារណាឃើញច្បាស់នូវផែនដីគឺអត្តភាពនេះផង នូវអបាយលោកទាំង ៤ ផង នូវមនុស្សលោកព្រមទាំងទេវលោកផង ព្រះសេខបុគ្គល ៧ ពួកលោកអាចនឹងពិចារណាឃើញច្បាស់ នូវបំណែកនៃធម៌គឺពោធិបក្ខិយធម៌ទាំង ៣៧ ដែលព្រះតថាគតទ្រង់សំដែងដោយប្រពៃ ដូចជានាយជាងក្រងផ្កាដែលឈ្លាសវាងវៃជ្រើសរើសនូវផ្កានោះបាន ។

## ធម្មបទេ ចតុត្ថោ បុប្ផវគ្គោ

មរីចិកម្មដ្ឋានិកភិក្ខុវត្ថុ

(២) ផេណូបមំ កាយមិមំ វិទិត្វា    មរីចិធម្មំ អភិសម្ពុធានោ

ឆេត្វាន មារស្ស បបុប្ផកានិ    អទស្សនំ មច្ចុរាជស្ស គច្ឆេ។

វិឌូឌភវត្ថុ

(៣) បុប្ផានិ ហេវ បចិនន្តំ    ព្យាសត្តមនសំ នរំ

សុត្តំ គាមំ មហោឃោវ    មច្ចុ អាទាយ គច្ឆតិ ។

## បុប្ផវគ្គទី ៤ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងមរីចិកម្មដ្ឋានិកភិក្ខុ*

(២) ភិក្ខុជាព្រះខីណាស្រពដឹងច្បាស់នូវកាយនេះថា ជាសភាវៈតាំងឡើងហើយតែងបែកធ្លាយទៅវិញ ដូចជាដុំពពុះទឹក ពុំនោះសោតដូចជាថ្ងៃបណ្ដើរកូន លោកក៏កាត់នូវវដ្ដប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាផ្កាឬជាបំណាំនៃមារបានហើយ ក៏ត្រេបទៅកាន់ព្រះនិព្វានដែលមិនមែនជាទីមើលឃើញរបស់មច្ចុរាជ (គឺជាមិនមែនជាវិស័យរបស់មច្ចុរាជឡើយ) ។

*គាថាក្នុងរឿងវិឌូឌភ*

(៣) មែនពិត មច្ចុរាជគឺសេចក្ដីស្លាប់ រមែងនាំយកនូវជនដែលមានចិត្តជាប់ក្នុងអារម្មណ៍ផ្សេង ៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណទាំង៥មែនពិត ដូចទឹកជំនន់ធំដែលនាំយកអ្នកស្រុកកំពុងដេកលក់ ដោយសេចក្ដីប្រហែសធ្វេសដូច្នោះឯង ។

# ធម្មបទេ បតុត្ថោ បុប្ផវគ្គោ

បតិពូជិកាវត្ថុគាថា

(៤) បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសន្នរំ
អតិត្តំ[១] យេវ កាមេសុ អន្តកោ កុរុតេ វសំ ។

មច្ឆរិយកោសិយសេដ្ឋិវត្ថុគាថា

(៥) យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ[២]
បលេ្លតិ រសមាទាយ ឯវំ គាមេ មុនី ចរេ ។

---

១ ម. អត្តញ្ញេវ ។ ២ ម. វណ្ណគន្ធមហេឋយំ ។

## បុប្ផវគ្គទី ៤ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបតិបូជិកា*

(៤) មួយវិញទៀត សេចក្ដីស្លាប់រមែងធ្វើនូវសត្វដែលមានចិត្តជាប់នៅក្នុងអារម្មណ៍ផ្សេង ៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណទាំង ៥ មែនពិត មិនឆ្អែតក្នុងវត្ថុកាមនិងកិលេសកាមទាំងឡាយនោះឯង ឲ្យលុះក្នុងអំណាចរបស់ខ្លួន ។

*គាថាក្នុងរឿងមច្ឆរិយសេដ្ឋី*

(៥) សត្វកន្លង់ឬឃ្មុំមិនដែលបៀតបៀនផ្កាក្ដី ពណ៌ក្ដី ក្លិនក្ដី ឲ្យវិនាសឲ្យខូចទេ គ្រាន់តែជញ្ជាប់យកតែរសជាតិហើយហើរទៅយ៉ាងណាមិញ ឯអ្នកប្រាជ្ញដែលទ្រទ្រង់ភេទជាបព្វជិតជាសេខឬអសេខ កាលបើត្រេចទៅក្នុងស្រុកទទួលយកនូវភិក្ខាតាមលំដាប់នៃត្រកូល មិនបានធ្វើនូវសទ្ធានិងភោគសម្បត្តិនៃត្រកូលឲ្យវិនាស ក៏យ៉ាងដូច្នោះឯង ។

# ធម្មបទេ ចតុត្ថោ បុប្ផវគ្គោ

បាវេយ្យអាជីវកវត្ថុគាថា

(៦) ន បរេសំ វិលោមានិ ន បរេសំ កតាកតំ

អត្តនោវ អវេក្ខេយ្យ កតានិ អកតានិ ច ។

ឆត្តបាណិឧបាសកវត្ថុគាថា

(៧) យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ

ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្ពតោ ។

## បុប្ផវគ្គទី ៤ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបាវេយ្យកាជីវក*

(៦) ពាក្យជាហេតុផ្ដាច់បង់នូវសេចក្ដីស្រឡាញ់ គឺពាក្យសំដីអាក្រក់របស់ជនទាំងឡាយដទៃ បុគ្គលមិនគាប្បីយកចិត្តទុកដាក់ឡើយ អំពើកម្មដែលជនទាំងឡាយដទៃបានធ្វើក្ដី មិនបានធ្វើក្ដី បុគ្គលក៏មិនត្រូវរិះគន់ស្ដីថាអ្វី ៗ ឲ្យគេដែរ ត្រូវតែរំពឹងពិចារណាអំពើរបស់ខ្លួន ដែលខ្លួនបានធ្វើក្ដី មិនបានធ្វើក្ដី តែម្យ៉ាង ៗ

*គាថាក្នុងរឿងឆត្តបាណិឧបាសក*

(៧) ជាតិផ្កាដែលរុងរឿងមានពណ៌ល្អតែគ្មានក្លិនក្រអូបយ៉ាងណាមិញ ឯសុភាសិតវាចាគឺពាក្យដែលព្រះសាស្ដាចារ្យទ្រង់ត្រាស់សំដែងដោយប្រពៃ ទៅជាមិនមានផលប្រយោជន៍ដល់បុគ្គលដែលមិនប្រតិបត្តិធ្វើតាមដោយល្អ ក៏យ៉ាងនោះដែរ ៗ

## ធម្មបទេ ចតុត្ថោ បុប្ផវគ្គោ

យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សុគន្ធកំ
ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្ពតោ ។

### វិសាខាវត្ថុគាថា

(៨) យថាបិ បុប្ផរាសិម្ហា កយិរា មាលាគុលេ[១] ពហូ
ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ ។

### អានន្ទត្ថេរបញ្ហាវត្ថុគាថា

(៩) ន បុប្ផគន្ធោ បដិវាតមេតិ ន ចន្ទនំ តគរមល្លិកា វា
សតញ្ច គន្ធោ បដិវាតមេតិ សព្វា ទិសា សប្បុរិសោ បវាយតិ

---

១ មាលាគុណេតិបិ បាឋោ ។

បុប្ផវគ្គទី ៤ ក្នុងព្រះធម្មបទ

ជាតិផ្កាដែលរុងរឿងមានពណ៌ល្អ ក្លិនក្រអូបផ្សព្វផ្សាយ យ៉ាងណាមិញ ឯសុភាសិតវាចាគឺពាក្យដែលព្រះសាស្តាចារ្យ ទ្រង់ត្រាស់សំដែងដោយប្រពៃ ជារបស់មានផលប្រយោជន៍ ដល់បុគ្គលដែលប្រតិបត្តិធ្វើតាមដោយល្អ ក៏យ៉ាងនោះឯង ។

*គាថាក្នុងរឿងនាងវិសាខា*

(៨) នាយជាងក្រងផ្កាបេះធ្វើសំណុំបាច់នៃផ្កាកម្រង ឲ្យបានច្រើនអំពីគំនរនៃផ្កា (ផ្សេង ៗ គ្នា) យ៉ាងណាមិញ សត្វលោកដែលកើតមកហើយ ក៏ត្រូវតែធ្វើកុសលឲ្យបានច្រើន យ៉ាងនោះឯង ។

*គាថាក្នុងរឿងអានន្ទត្ថេរបញ្ហា*

(៩) ក្លិនផ្កា (ទាំងពួង) មិនអាចផ្សាយទៅ កាន់ទីច្រាសខ្យល់បានទេ ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាឥតក្លិនខ្ចាំពាក់ក្តី ក៏មិនអាចផ្សាយទៅកាន់ទីច្រាសខ្យល់បានដែរ មានតែក្លិនគឺសីលរបស់សប្បុរសទាំងឡាយ ទើបផ្សាយទៅកាន់ទីច្រាសខ្យល់បាន ឯសប្បុរស (តែងមានក្លិនក្រអូបគឺសីល) ផ្សាយទៅកាន់ទិសទាំងពួងបាន ។

## ធម្មបទេ ចតុត្ថោ បុប្ផវគ្គោ

ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី
ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។

### មហាកស្សបត្ថេរវត្ថុគាថា

(១០) អប្បមត្តោ អយំ គន្ធោ យ្វាយំ តគរចន្ទនី(១)
យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ ។

### គោធិកត្ថេរវត្ថុគាថា

(១១) តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ
សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។

---

១ ម. តគរចន្ទនំ ។

## បុប្ផវគ្គទី ៤ ក្នុងព្រះធម្មបទ

ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាឧប្បលក្តី ពុំនោះសោតក្លិនផ្កាម្លិះលាក្តី ក៏ក្រអូបមែនហើយ តែឯក្លិនគឺសីលប្រសើរបំផុត ជាងគន្ធជាតិទាំងឡាយមានខ្លឹមចន្ទន៍ជាដើមនេះទៅទៀត ។

*គាថាក្នុងរឿងមហាកស្សបត្ថេរ*

(១០) ក្រអូបខ្លឹមក្រស្នានឹងខ្លឹមចន្ទន៍ឯណា ក្រអូបទាំងនេះឈ្មោះថាក្រអូបមានប្រមាណតិច ក្លិននៃបុគ្គលមានសីលទាំងឡាយ ឈ្មោះថាក្រអូបដ៏លើសលុប តែងផ្សាយទៅក្នុងទេវលោកនឹងមនុស្សលោកទាំងឡាយបាន ។

*គាថាក្នុងរឿងគោធិកត្ថេរ*

(១១) មារាធិរាជ (ទុកជាស្វែងរក) ក៏មិនបាន (មិនឃើញ) នូវផ្លូវរបស់ព្រះខីណាស្រពទាំងឡាយនោះ ដែលលោកបរិបូណ៌ដោយសីល មានប្រក្រតីនៅដោយសេចក្តីមិនប្រមាទ មានចិត្តផុតស្រឡះហើយ (ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះលោកដឹងច្បាស់នូវធម៌ដោយប្រពៃ ។

# ធម្មបទេ បញ្ចមោ ពាលវគ្គោ

## គរហទិន្នវត្ថុគាថា

(១២) យថា សង្ការដ្ឋានស្មឹ[១] ឧជ្ឈិតស្មឹ មហាបថេ
បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ ។
ឯវំ សង្ការភូតេសុ អន្ធភូតេ[២] បុថុជ្ជនេ
អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធសាវកោ ។

បុប្ផវគ្គោ ចតុត្ថោ សមត្តោ ។

## អញ្ញតរបុរិសវត្ថុគាថា

(១) ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ
ទីឃោ ពាលានសំសារោ សទ្ធម្មំ អវិជានតំ ។

---

១ សង្ការធានស្មិន្តិបិ បាឋោ ។ ២ ម. អន្ធិភូតេ ។

# ពាលវគ្គទី ៥ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងគរហទិន្ន*

(១២) គំនរសម្រាមដែលគេចាក់ចោលក្បែរផ្លូវធំ ហើយមានផ្កាឈូកដុះឡើងលើគំនរសម្រាមនោះ មានក្លិនក៏រំងរឹតតែក្រអូបល្អ ហើយជាទីជម្រែកនៃចិត្តផង មានឧបមាដូចម្តេចមិញ ។ ក៏ឯសាវករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ (កាលបើលោកិយមហាជនទាំងឡាយដ៏មានកិលេសក្រាស់) ដូចជាគំនរសម្រាមកើតឡើងហើយ លោកក៏ទៅជាបុគ្គលរុងរឿងកន្លងបង់នូវបុថុជ្ជនទាំងឡាយ ដែលមានងងឹតច្រើនហើយគឺមិនមានបញ្ញាចក្ខុ ដោយបញ្ញារបស់ខ្លួន ក៏មានឧបមេយ្យដូច្នោះឯង ៚

**បុប្ផវគ្គទី ៤ ចប់**

*គាថាក្នុងរឿងអញ្ញតរបុរស*

(១) រាត្រីក៏យូរវែង ដល់បុគ្គលដែលភ្ញាក់រឭករឿយ ៗ យោជន៍(១) តែងវែងឆ្ងាយ ដល់បុគ្គលកាលដើរនឿយហត់ (តាមផ្លូវ) សង្សារវដ្តតែងវែងឆ្ងាយ ដល់បុគ្គលពាល ដែលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

# ធម្មបទេ បញ្ចមោ ពាលវគ្គោ

មហាកស្សបសទ្ធិវិហារិកវត្ថុគាថា

(២) ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ
ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។

អានន្ទសេដ្ឋិវត្ថុគាថា

(៣) បុត្តាមត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។

# ពាលវគ្គ ទី ៥ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងមហាកស្សបសទ្ធិវិហារិកភិក្ខុ*

(២) បុគ្គលស្វែងរក (កល្យាណមិត្ត) បើមិនបានមិត្តដ៏ប្រសើរស្មើនឹងខ្លួនទេ ត្រូវធ្វើកិរិយាប្រព្រឹត្តប្រតិបត្តិតែឯកឯងឲ្យខ្ជាប់ខ្ជួន (ក្នុងឥរិយាបថទាំង ៤) ព្រោះថាសហាយតាគុណ[១] មិនមាន ក្នុងបុគ្គលពាលឡើយ ។

*គាថាក្នុងរឿងអានន្ទសេដ្ឋី*

(៣) បុគ្គលពាលតែងក្តៅក្រហាយព្រួយលំបាកដោយគិតដូច្នេះថា កូនទាំងឡាយរបស់អាត្មាអញមាន ទ្រព្យរបស់អាត្មាអញមាន, តែខ្លួនរបស់ខ្លួនមិនមានទៅហើយ បំណាច់បើកូនទាំងឡាយនឹងមានមកពីណា ទ្រព្យរបស់នឹងមានមកពីណាបាន ។

---

១ អដ្ឋកថា ថា ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាមគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ ហៅថាសហាយតាគុណ ក្នុងទីនេះ ។

# ធម្មបទេ បញ្ចមោ ពាលវគ្គោ

គណ្ឋិភេទកចោរវត្ថុគាថា

(៤) យោ ពាលោ មញ្ញតិ ពាល្យំ បណ្ឌិតោ វាបិ តេន សោ
ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតិ ។

ឧទាយិត្ថេរវត្ថុគាថា

(៥) យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។

តឹសមត្តាបាវេយ្យកភិក្ខុវត្ថុគាថា

(៦) មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។

# ពាលវគ្គទី ៥ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងគណ្ឋិភេទកចោរ*

(៤) អ្នកណាជាមនុស្សពាលហើយដឹងខ្លួនថាជាពាលមែន អ្នកនោះព្រះដ៏មានព្រះភាគឲ្យឈ្មោះថាជាអ្នកប្រាជ្ញបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះឯង ។

ម្យ៉ាងទៀតអ្នកណាជាមនុស្សពាលមានមានះប្រកាន់ថាខ្លួនជាបណ្ឌិតវិញ អ្នកនោះព្រះដ៏មានព្រះភាគឲ្យឈ្មោះថាជាមនុស្សពាលដោយពិត ។

*គាថាក្នុងរឿងឧទាយិត្ថេរ*

(៥) មនុស្សពាលនោះចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិតក្តី ក៏គតមានដឹងរសធម៌អាចអ្វីឲ្យច្បាស់លាស់ឡើយ ដូចគ្នានឹងវែកដែលមិនដឹងរសសំឡនោះឯង ។

*គាថាក្នុងរឿងតឹសបាវេយ្យកភិក្ខុ*

(៦) អ្នកប្រាជ្ញបើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេចក្តី ក៏ដឹងច្បាស់នូវរសធម៌អាចជាឆាប់រហ័សបាន ដូចគ្នានឹងអណ្តាតដែលដឹងច្បាស់នូវរសសំឡ ។

# ធម្មបទេ បញ្ចមោ ពាលវគ្គោ

សុប្បពុទ្ធកុដ្ឋិវត្ថុគាថា

(៧) ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា
ករោន្តា បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ ។

កស្សកវត្ថុគាថា

(៨) ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ ។
យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ ។

# ពាលវគ្គទី ៥ ក្នុងព្រះធម្មបទ

### គាថាក្នុងរឿងសុប្បពុទ្ធកុដ្ឋិ

(៧) អំពើកម្មឯណាដែលជាកម្មមានផលក្ដៅក្រហាយអោក្រក់ ពួកជនពាលអប្បឥតប្រាជ្ញា មានខ្លួនដូចសឹកសត្រូវ តែងធ្វើអំពើកម្មលាមកនោះ ហើយប្រព្រឹត្តទៅ ។

### គាថាក្នុងរឿងកស្សបឧបាសក

(៨) បុគ្គលធ្វើកម្មឯណាហើយ តែងក្ដៅក្រហាយជារឿយ ៗ (ឬ) បុគ្គលដែលមានមុខប្រទ្លាក់ដោយទឹកភ្នែក ស្រែកយំ បានសោយផលកម្មឯណា កម្មដែលបុគ្គលធ្វើហើយនោះមិនបានឈ្មោះថាជាកម្មល្អប្រពៃឡើយ ។



កូនសិស្សលោកសង្ឃនៅស្រុកភ្នូមា រែកសម្រាប់មកពីភូមិ ទៅវត្ត ។

# លោកន័យ

( ៦ )

បទបន្លែថា ហែមហោយក្សា នាបញ្ចរ៍ វាហៅមូលៈ តរធម៌ឯងតែ ជាសង្ខេបទេ ពិតពុំពិស្ដារ ។ រីកិលេសនៅ លោកនាសត្រ្វ ជា ១០ ប្រការ សឹងកើតពីចិត្ត គំនិតអន្ធពាល នេះហៅពិស្ដារ មូលតរធម៌ ។ ១ គឺទិដ្ឋិ ហេតុគិតរករិះ អ្វីខុសថាជា គាប់គួរសេចក្ដី ពុំពិចារណា យល់គាប់ថាជា ខុសវិញហើយរក ។ គ្រូងទៀតជា ពំនាក់អាត្មា ថាគាប់ ពុំយក ព្រះស្រីរ័តន៍ត្រៃ ថ្លាថ្លៃពន្លក ជាទីពឹងមក ពំនាក់ ឡើយណា ។ ១ គឺលោភនោះ ហេតុចិត្តចំពោះ ចង់បាន ទ្រព្យ ឧទ្ធំនោះចិត្ត ពុំគិតរក្សា សីលធម៌ភាវនា ជាបុណ្យ មគ្គផល ។ ១ គឺទោសោ ហេតុចិត្តលោភោ កំហឹងកំហាល់ ខឹងគុំចងពៀរ ពំនៀរអំពល់ ទោរង់ទុក្ខទល់ ពេកពន់ប្រមាណ ។ ១ គឺមោហា ហេតុពុំប្រាជ្ញា សម្បត្តិនិព្វាន ១ គឺកង្ខា ចិន្ដានោះមាន សន្ទេះក្នុងប្រាណ ពុំជឿព្រះធម៌ ។ ពុំជឿព្រះស្រី រ័តន៍ត្រៃទាំងបី ប្រសើរថ្លៃថ្លា ១ គឺថីន៍ មិទ្ធធម៌ថា ដេកលក់នៅនា ក្នុងវដ្ដសង្សារ ។ ១ គឺមានៈ ចិត្ត. ពោរប្រទះ ប្រទុស្ដស្រើបស្រាល រឹងប្ដឹងកំហែង អង្គឯង

អាសារ ប្រាំបីប្រការ កបនឹងលោកនាស ។ អហិរិកំ អនោ-
តប្បំ គឺចិត្តមិនខ្មាស មិនខ្លាចបាបឡើយ ព្រើយនិរាស
នេះហៅលោកនាស ទាំងពីរប្រការ ។ ជាកិលេសធម៌ ទាំង
១០ មានអាចិ អង្គឲ្យអាសារ នេះហៅមូលៈ តរធម៌ពិស្ដារ
គួរគិតពិចារ- ណាឲ្យអស់ក្ដី ។ បើអ្នកឯងអាច លះកាត់
កំណាច បោះបង់បេញក្ដី អ្នកនោះនឹងបាន និព្វានសោភី
សុខសិរីទ្ធី ដូចចិត្តប្រាថ្នា ។ ធម៌ ១ ប្រការ ហៅមហាពិស្ដារ
នោះយករូបា ប្រាំបីដណ្ដប់ គ្រាន់គ្រប់ហើយណា យកនាមធម៌-
បា សិបបីហើយយក ។ លក្ខណារូបា បីដុំនឹងអា- កាស
ធាតុមួយមក បូកជាបិតសិប ប្រាំទើបទាំងយក កិលេស ១០
មក គុណស្រេចហើយណា ។ ពីរគុណទៀតស្បាន់ ជាកិ-
លេសពាន់ រយហៅមហា វិត្ថារសូរេប ធម៌ស្រេចហើយណា
ឯអស់ទេត្ដា ទេព្រក្សផងក្ដី ។ សិងឲ្យស័ព្ទសា- ធុការម-
ហិមា កក្រើកប្រថពី ឥន្ទ្រីយក្ខយង់ ឱនអង្គវន្ទី ទៀបបាទ
ពោធិ សត្វសរសើរថា ។ បពិត្រអម្ចាស់ មានគុណធ្ងន់
ណាស់ ឥតឯឧបមា តាណាំជាហេន ឲ្យទានខ្ញុំជា បង្អែក

រូបា ជាទីមគ្គផល ។ លេណំជាយាន ខ្ញុំតួនតឹងប្រាណ នឹងអកុសល ទីបីបំពោះ ជាកោះថ្នាក់ថ្កល់ នាថខ្ញុំយល់ ម្ចាស់ ជាពំនាក់ ។ សរណំជាស្ពាន ឲ្យខ្ញុំសួបាន ដួចដល់ផលមគ្គ បរិបូណ៌លុះបាន និព្វានជៀងជាក់ ខ្ញុំឥតពំនាក់ ឯទៀត ឡើយណា ។ មានតែម្ចាស់ថ្លៃ ប្រសើរលើសក្រៃ សូមម្ចាស់ មេត្តា យកខ្ញុំជាសិស្ស ម្ចាស់ជាអាចារ្យ អញខ្ញុំសោតណា នៅធ្វើគុណស្នង ។ កាលនោះសោតណា អស់ទាំងទេព្តា ទេព្រក្សព្រឹក្សផង សុំពរប្រទ័ក្ស សិណាអ្នកបីជង ហើយហិប ហោះផ្សង ទៅកេនអាត្មា ។

នេះបទភុជង្គបរោ ឯអង្គព្រះមហា ក្សត្រក្សត្តធិបតី ។ ទៅថ្មមបីបមពោធិ សត្វជាក់បុះពី លើគ្រែអាស្នា ។ ឱនឱប ក្រសោបអង្គា បើបហើយត្រាស់ថា ហៃហៅធនញ្ជ័យ ។ ផ្សែរលែងតែហៅឯងនៃ អញឥតអាស្រ័យ នឹងអ្នកឯណា ។ ទោះបីមន្ត្រីយោធា បរោហិតា ឧបរាជក្តី ។ មាតាបុត្រាបុត្រី ទាំងរាជទេពី សំឡាញ់ស្នេហ៍ស្និទ្ធ ។ នឹងបានមកជួយជីវិត ដួចហៅឯងឥត អង្គីមានឡើយ ។ ព្រះមហាក្សត្រាត្រាណត្រើយ

សរសើរហោះហើយ ពហ៍ពង្សពោធិ ។ ព្រះអង្គឡើងគង់ដិរី អស់មុខមន្ត្រី ហែក្សត្រឧត្តម ។ បាំងក្លស់ខ្ពង់ខ្ពស់ត្រសុំ ត្រសាយល្បុំ វិលប្កានសីមា ។ រីឯនន្ទយក្សា សឹងតាមព្រះមហា បុរសរ័តន៍ទៅ ។ លុះដល់មណ្ឌលលំនៅ សាលព្រឹក្ស ១ក្រៅ បាបិនគាមា ។ កុមារត្រអាលទូលថា បពិត្រព្រះមហារាជសូមព្រះអង្គ ។ បញ្ឈប់នៅម្លប់នេះវង់ បានតិបស្ដេចគង់សម្រានអង្គា ។ ស្ដេចគង់នៅម្លប់នោះណា កាលនោះយក្សាមកទៀបពោធិ ។ អ្នកជាហៃបានន្ទ យក្ខអើយកុំបី តាមអញឡើយណា ។ យក្ខស្ដាប់សារសព្វរាប បួលទៅនៅនាសាលព្រឹក្សនោះនៃ ។ ពោធិសត្វវិសេសថ្លៃ ទូលក្សត្រជេស្ឋជ័យ ឲ្យស្ដេចចេញចរ ។ ទៅដល់មណ្ឌលនគរ ទើបព្រះភូធរពហ៍ពោធិសត្វ ។ លេលាឡើងប្រាសាទរ័តន៍ ទើបស្ដេចគង់ថិតលើរាជអាសនា ។ ព្រះសួរបន្ទូលត្រាស់ថា ហៃធនញ្ជ័យមហាសេដ្ឋីអើយពៅ ។ សម័យពីថ្ងៃនេះទៅ ព្រះស្ដែងឲ្យពៅធនញ្ជ័យកុមារ ។ មកជាបុត្រាសង្សារ អញនឹងព្យាបាល ទុកស្មើបុត្រា ។ សេដ្ឋីរន្ធទូលថា ទ្រង់ព្រះមេត្តា តាមសព្វព្រះទ័យ ។

ព្រមស្រេចទើបស្តេចបងដៃ អភិសេកធនញ្ជ័យ កុមារទុកជា ។
រាជបុត្របរិសុទ្ធស្នេហា សម្តេចក្សត្រា ឲ្យសង់ប្រាសាទ ។
មួយធំពិតពុំឲ្យឃ្លាត ឆ្ងាយពីព្រះបាទ ខាងទិសបូព៌ា ។
សង់ស្រេចស្តែងស្តេចឲ្យជា លំនៅព្រះមហា បុរសរ័តន៍ថ្លៃ ។
ឲ្យជូនជំនូនក្នុងថ្ងៃ មីមួយបិទ្រៃ មួយសែនមហិមា ។
ធនញ្ជ័យសេដ្ឋីសោតណា ទ្រង់ព្រះមេត្តា ឲ្យទ្រព្យរបស់ ។
ឲ្យទាំងកន្សាំងនូវអស់ ប្រដាប់ស័ក្តិយស ជាធំលើសក្រៃ ។
ពោធិសត្វវិសេសថ្លៃ ចាប់ដើមពីថ្ងៃ នោះទៅហើយណា ។
ឲ្យបបរមធុបាយាស ជូនផែយក្ខយស ព្រឹកល្ងាចសព្វថ្ងៃ ។
កុមារពិសាលថ្លាថ្លៃ ល្អើងប្រាកដក្រៃ ដូចព្រះចន្ទ្រា ។
ពេញបូណ៌យង់យល់ជ្រះថ្លា ពុំនោះសោតណា ដូចព្រះអា-
ទិត្យ ។ ឱទ័យប្រពៃទ្រង់រិទ្ធិ ពេញពន្លឺភិត កណ្តាលវេហាស៍ ។
កើតយសរបស់ទ្រព្យា កើតលាភដោយអា-នុភាពខ្លាចឯង ។
ពោធិសត្វវិសេសថ្លែង ជាប្បាប់សំដែង សរសើរប្រាជ្ញា ។
ព្រះពុទ្ធស្តេចទ្រង់ទេស្នា សឹងសរសើរថា សីលធម៌សប្បុរស ។
ទោះមានធនធានរបស់ មានស័ក្តិមានយស សឹងតាមប្រាជ្ញា ។

ដូចផ្កាយទាំងឡាយយាត្រា តាមព្រះចន្ទ្រា កណ្ដាលអម្ពរ ។
ពណ៌នាប្រស្នាមូលគរ ធម៌ចប់ស្រេចបវរ បូណ៌បទម្ល៉េះណា ។

នេះបទពំនោលបរបា ថ្លែងពីព្រះមហា ពន្លកបុរសរតន៍ថ្លៃ ។ បម្រើមហាក្សត្រដេស្ឋជ័យ មានកាល ១ ថ្ងៃ អ្នកឡើងទៅគាល់ក្សត្រា ។ ស្ដេចចេញបុងរោងក្រលា គំនាល់សេនាមន្ត្រីគង់គាល់ចក្រី ។ ស្ដេចទតយល់ព្រះពោធិ៍ កើតក្ដីបីតីមានព្រះបន្ទូលត្រាស់ថា ។ ហៃរាជបុរោហិតា ចូរមើលទៅនាអ្នកប្រាជ្ញប្រសើរដើរមក ។ អញគិតចង់ឲ្យរិះរក ក្មេង ៗ ផងមក ឲ្យជាអ្នកប្រាជ្ញឈ្មោះណា ។ បុរោហិតក្រាបទូលថា បើឈ្មោះក្សត្រា ត្រាស់ឲ្យស្វែងអស់ក្មេងផង ។ ទើបពោធិសត្វប្លាស់ប្លង ដល់ទៅហើយហោង ក្រាបថ្វាយបង្គំក្សត្រា ។ ទើបស្ដេចបន្ទូលត្រាស់ថា ធនញ្ជ័យអើយបា ឥឡូវប្រសិនបើមាន ។ ក្មេងជាអ្នកប្រាជ្ញទៀតបាន គាប់ឬមួយមាន តែចៅម្នាក់ឯងក៏គាប់ ។ ព្រះពោធិសត្វស្ដែងស្ដាប់ អស់អាថ៌សារសព្ទ បង្គំប្រណម្យទូលថា ។ បពិត្រមានច្រើនណោះជា បើស្ដេចប្រាថ្នា នឹងចង់បានហើយត្រាស់ស្វែង ។ ដណ្ដឹងចោទ

អស់ក្មេងផង ស្តេចបន្ទូលស្នង ថាឈ្មោះយើងល្បងនឹងអ្វី ។ ពោធិសត្វទូលវិញឲ្យ គួរយើងល្បងពី អាថ៌សាធុកិច្ចបញ្ហា ។ ថាបើមានក្មេងឯណា មួយមានប្រាជ្ញា ឆ្លើយបានហើយយកមកឲ្យ ។ ស្តេចស្តាប់ទើបព្រះចក្រី ហៅអមាត្យបី នាក់មកហើយស្តេចត្រាស់ថា ។ ចូរព្រះស្តែងបរយាត្រា ទៅឯគាមា បស្ចិមទក្សិណឧត្តរ ។ បានមហាសេដ្ឋីបវរ ឲ្យហៅក្មេងចរ- បូណ៌បាន ៧ ឆ្នាំណា ។ មកចោទដណ្តឹងអាថ៌សា- ធុកិច្ចបញ្ហា បើក្មេងឯណាអាចឆ្លើយ ។ ដោះសារអាថ៌នេះបានហើយ កុំផ្សូផ្សងឡើយ ព្រះស្តែងនាំចូលមកឲ្យ ។ កាលនោះអមាត្យទាំងបី ក្រញក្រាបសិរសី ប្រណម្យបង្គំលុតលា ។ អមាត្យមួយបរយាត្រា ទៅស្រុកទក្ខិណាដល់ផ្ទះវិសាលសេដ្ឋី ។ ថ្លែងព្រះអាជ្ញាចក្រី សព្វគ្រប់សេចក្តីប្រាប់មហាសេដ្ឋីនោះហោង ។ សេដ្ឋីឲ្យរកក្មេងផង ក្នុងស្រុកនោះហោង បានក្មេងមួយរយបំហុត ។ សឹងកើតខែចេត្រប្រាកដ ប្រាំពីរឆ្នាំគត់ ឲ្យហៅចូលមកជួបជុំ ។ សេដ្ឋីសង់រោងមួយធំ អង្គុយជំនុំ ស្រេចហើយទើបរាជអមច្ចា ។ ដណ្តឹង

អស់ក្មេងនោះថា អ្វីយើយហៅសា- ធុកិច្ចជាក្រិត្យប្រពៃ ។ អស់ក្មេងពុំដឹងឡើយនែ នៅស្មៀមទីទៃ កាលនោះមាន កូនជិកទង ។ ឈ្មោះទេសកុមារឆ្លើយស្នង ថារីក្រិត្យផង ហៅសាធុកិច្ចប្រពៃ ។ បើអ្នកឯណាមួយនែ មានស័ក្ដិយសថ្លៃ ដេកនៅហើយភ្ញាក់រឭក ។ ដោះឡើងពីដេកនាព្រឹក ទន់ ហើយងូតទឹក ជំរះញើសក្អែលអាត្មា ។ ហើយមកបរិភោគ អស់អា- ហារផងពីសា ហើយដេកទៅលើកំរាល ។ លក់ លេងសប្បាយត្រអាល រសៀលស្រយាល ដោះឡើងងូត ទឹកទៀតណា ។ ហើយលាបគ្រឿងគន្ធមាលា ឬតបារភ្ញីផ្កា ប្រដាប់គ្រឿងផងទាំងឡាយ ។ ដើរលេងក្រសាលសប្បាយ កុំគិតព្ធញបាយ ទំនិញទំញូងដូរឡើយណា ។ កុំបំផ្លើស្រែ បំការ ឈ្មោះហោងហៅសា- ធុកិច្ចគឺក្រិត្យនោះឯង ។ រីទេស កុមារសំដែង សរសើរប្លាថ្លែង សភាពខ្លឹលបំរាជាគាប់ ។ ឯរាជអមាត្យស្ដែងស្ដាប់ ហើយវិលត្រឡប់ នាំទេសកុមារ យាត្រា ។ រីរាជអមាត្យមួយណា ទៅស្រុកបប្ចិមា ដល់ផ្ទះ សុបិសេដ្ឋី ។ ថ្លែងប្រាប់សព្វគ្រប់សេចក្ដី ទើបមហាសេដ្ឋី

ឲ្យដើររើសអស់ក្មេងផង ។ បានប្រាំពីររយហើយហោង នាំមកត្រសង ជួបជុំនៅមហាសេដ្ឋី ។ អមាត្យដណ្តឹងទៅខ្មី ថា ហៃក្មេងអ្វី ហៅសាធុកិច្ចប្រសើរ ។ ក្មេងផងពុំដឹងដំណើរ នៅស្ងៀមហើយមើល មុខគ្នាពុំហ៊ានឧបរហ ។ មានកូនអ្នកប្រមឹកស្រា មួយនោះនាមា ឈ្មោះសុបកុមារឆ្លាស់ឆ្លើយ ។ ថា ហៃអ្នកអមាត្យអើយ អ្នកណាមួយហើយ ប្រកបនូវស្រីសួស្តី ។ បើចង់មើលរូបអ្វីៗ ឲ្យមើលកុំបី ឃាត់ភ្នែកបើនឹងចង់ស្តាប់ ។ ភ្លេងភ្លាត់បម្រៀងសូរសព្ទ ឲ្យប្រព្រឹត្តស្តាប់ កុំឃាត់ត្រចៀកឡើយណា ។ បើចង់ថើបក្លិនគន្ធា ពិដោរក្តីណា កុំឃាត់ច្រមុះឡើយហោង ។ ទោះបីធីអាហារផង ឲ្យបរិភោគហោង កុំឃាត់ឲ្យខានអាហារ ។ បើចង់ឲ្យព្រួននិកម្រាលស្លៀកពាក់ត្រអាល ឲ្យផ្សព្វកុំឃាត់អាត្មា ។ សុបកុមារថ្លែងថា អ្នកគិតសីលជា ប្រសើរហេតុបិត្តអន្តពាល ។ អមាត្យស្តាប់ហើយត្រអាល នាំសុបកុមារ ឆ្ពោះទៅថ្វាយព្រះភូធរ ។ ឯអមាត្យ ១ ចេញចរ ទៅទិសឧត្តរ ប្រាយប្រាប់សុទសសេដ្ឋី ។ បានក្មេង៥រយមកខ្មី ដណ្តឹងហេតុពី អាបិសាធុកិច្ចបញ្ហា ។

គឺក្រិត្យប្រិពៃថ្លៃថ្លា  អស់ក្មេងនោះណា  ពុំដឹងដំណឹងសូន្យ សោះ ។ មានកូនអ្នកលេង ១ ឈ្មោះ ជិកកុមារនោះ ឆ្លើយថា រីអ្នកឯណា ។ មួយមានអំណាចបេស្តា  តិះដៀលនិន្ទា រំលឹកជេរពោលគេក្តី ។ តាមដោយនូវហេតុអ្វីៗ  អ្នកនោះស្រដីជាស់តឿនបុកបែនសំឡាប់ ។ ដោយហេតុអំពើពុំគាប់ នឹងឮសួរសព្ទ មានជ័យអ្នកផងស្រប់ស្រែង ។ ឯជិកកុមារសំដែង អ្នកសាហាវឯង  ពុំដឹងក្តីថាជាគាប់  ។ រីរាជអមាត្យបានស្តាប់ អស់អាថ៌សារសព្ទ នាំជិកកុមារមកខ្ញុំ ។ ប្ដូលថ្វាយព្រះបាទបក្រីអមាត្យទាំងបី  ដល់ព្រមថ្ងៃ ១ ផងគ្នា  ។  អមាត្យបង្គំវន្ទាក្រាបទូលក្សត្រា  ដោយនូវដំណើរនោះហោង ។

បទកាកគតិ  ស្តេចស្តាប់ពាក្យពី  អមាត្យទូលស្នង ទ្រង់ព្រះអំណរ  សាទរក្នុង  ដ្បិតបានដូចប៉ង  ព្រះទ័យប្រាថ្នា ។ ក្សិណក្សត្របា្រស់ប្រឹង  ដំណាំងក្មេងផង  ពីអាថ៌បញ្ហា  អស់ក្មេងបង្គំ  ប្រណម្យក្សត្រា  ទូលដូចពាក្យថា  មុនមកនោះហោង ។ ទើបស្តេចដំណាំង  ព្រាហ្មណ៍ព្រឹទ្ធថាក្មេង  ទាំងនេះជាម្តង  ជាអ្នកប្រាជ្ញា  អង្គីប្រាជ្ញផង  ទើបព្រាហ្មណ៍ទូល

ស្ទង់ បពិត្រក្សត្រថ្លៃ ។ ក្មេងនេះឯងអាច ដាក់ជាអ្នកប្រាជ្ញ កុំម្ចាស់សង្ស័យ ស្ដេចដណ្ដឹងទៅ កាន់ហោធនញ្ជ័យ ថាក្មេងនេះនែ ប្រាជ្ញឬពុំប្រាជ្ញ ។ ពោធិសត្វទូល បពិត្រឥស្សរភូមិន្ទ្ររាជ ក្មេងនេះហៅឆ្លាស់ ឱកាសឯងអាច ពុំជាអ្នកប្រាជ្ញប្រាកដឡើយហោង ។ ស្ដេចបន្ទូលថា ហេតុម្ដេចចូរបាប្រាយប្រាប់អញផង ឲ្យបានអញដឹង ដំណឹងទំនង ពោធិសត្វសង់ ទូលទៅទៀតថា ។ បពិត្រភូមី ក្មេងនេះស្រដី ពុំត្រូវធម្មា អ្នកប្រាជ្ញឧត្តម ពិតពុំដែលថា ពាក្យដូច្នេះជា ប្រប្រសើរឡើយហោង ។ ក្មេងឆ្លើយប្រថម នោះសរសើរអំ- ពីអ្នកខ្ជិលផង បង់តែស្អាតខ្លួន នោះកូនដឹកទង ប្រាកដកន្លងកុំបីសង្កា ។ ក្មេងឆ្លើយអណ្ដាប់ សរសើរថាគាប់ គួរឯតណ្ហាឥតសីលសូន្យសោះ ក្មេងនោះឯងជា កូនប្រមឹកស្រា ប្រាកដជាក់ស្ដែង ។ ក្មេងឆ្លើយក្រោយនោះ សរសើរបំពោះ អ្នកសាហាវឯង ចិត្តច្រើនកំហឹង ខេរខឹងឥតក្រែង នោះកូនអ្នកលេងស់សន់ឥតត្រើយ ។ ស្ដេចដណ្ដឹងថា អ្នកប្រាជ្ញបរហា ដូចម្ដេចហៅអើយ ពោធិសត្វស្ដាប់ សារស័ព្ទនោះហើយ បង្គំទូល

ឆ្លើយ ជាបទគាថា ។ នសាធុអ លសោភាជ រីអ្នកឯណា បើប្រើនខ្ជិលហើយ ឥតត្រើយអង្គអា- សាស្ទ្យសោះសារ ពុំប្រសើរឡើយ ។ នសាធុយា អសញ្ញតោ អ្នកឥតសីល ហើយ កាន់តាមគុណ លោភលន់ឥតត្រើយ ពុំប្រសើរឡើយ ជាអ្នកមោហា ។ នសាធុកោ-ធុបនាហោ រីអ្នកឯណា មួយ បើប្រើនខឹង កំហឹងមហិមា អ្នកប្រាជ្ញលោកថា ពុំប្រសើរ ឡើយ ។ ទើបស្ដេចបន្ទូល ថានាត្រកូល ក្មេងទាំងនេះ ហើយ ចៅដឹងដោយកិច្ច កលស្ដេចចៅអើយ ពោធិសត្វឆ្លើយ សូត្រជាបាឡី ។ អាហរោមា ខ្យាតិកលោ ធម៌លោកស្រដី ថាមារយាទឯង សំដែងប្រាប់ពី ត្រកូលជីនី ជីនកអាត្មា ។ ហខ្យាតិទេ សភាសិតេ លោកថាភាសា សំដីខ្លួនឯង សំ- ដែងអាត្មា ប្រទេសភោនណា ដឹងដោយនោះហោង ។ មិត្ត ខ្យាតិ សម្ភាសិ លោកថាអ្នកផង ជាមិត្របានគប់ ប្រសព ស្នេហ៍ស្នង ទៅមកនោះហោង សំដែងស្រឡាញ់ ។ វិបុរាខ្យា តិភោជនា ស្គមជាត់នោះមិញ អាហារនោះឯង សំដែងប្រាប់ វិញ បួលពុំបួលមិញ ដឹងដោយនោះហោង ។ ហេតុមាន

បាឡី ធម៌លោកស្រដី ដូច្នេះជាមួង ទើបដឹងត្រកូល អម្បូរ
កន្លង អ្នកទាំងនេះហោង ដោយហេតុនោះណា ។ ឯអ្នក
ទាំងបី ស្ដាប់ពាក្យពោធិ- សត្វសិរីវង្សា ជៀលតិះប្ដេះនៃ
ខឹងក្រៃមហិមា ជាទោសគុំមហា បុរសរ័តន៍ថ្លៃ ។ កាល
នោះព្រះបាទ ធនញ្ជ័យនរនាថ ធិរាជជេស្ឋជ័យ ស្ដាប់ពាក្យ
ពោធិ- សត្វវិសេសថ្លៃ មានព្រះហឫទ័យ អាសូរករុណា ។
ស្រឡាញ់អ្នកពាល ទូរជនស្រើបស្រាល បន្ទូលត្រាស់ថា
អ្នកទាំងឡាយគ្រប់ គ្រងម្ដាយនៅអា- ពុកញាតិកា នៃអ្នក
ប្រាជ្ញផង ។ ទោះបីថយហោក ដូចម្ដេចក្ដីលោក ពុំគិត
ឡើយហោង លោកយកតែប្រាជ្ញ ឯងអាចជាម្ដង មានច្បាប់
លោកបង ជាបទគាថំ ។ យថាកលតោ បុប្ផសេលោ ម-
ណិជាតំ គទ្រភូតា អជានិយំ បណ្ឌិងវំ ជាតិយោតិ ។ លោក
ថាកំណើត ផ្កាផងសឹងកើត ពីភក់ឯងង អ្នកផងបេះយក
វាមកជ្បិតពិ- ដោរ ១ សោតមណី រ័តន៍ផងទាំងឡាយ ។
សឹងកើតពីថ្ម អ្នកផងយល់ល្អ រស្មីព្រោងព្រាយ យកជា
ទ្រព្យា ប្រដាប់អង្គកាយ ដូចកល់ប្រាជ្ញប្រាយ កើតពីសន្តាន ។

ហោកបយក្ដីយក តែប្រាជ្ញមក ជាតិជាប្រធាន បន្ទូលម៉្លោះ
ស្រេច ទើបស្ដេចប្រទាន របស់យសយាន ក្មេងផងនោះនៃ ។
កូនជកទងនោះ ស្ដែងស្ដេចឲ្យឈ្មោះ សុន្ទរាល័យ ឯកូនអ្នក
លេង ព្រះមហាក្សត្រថ្លៃ ឲ្យឈ្មោះអភ័យ បណ្ឌិតជាម្ដង ។
កូនប្រមឹកស្រោ ឲ្យឈ្មោះឥដ្ឋា- រម្មណ៍បណ្ឌិតហោង ស្ដេចឲ្យ
គ្រឹះឋាន គ្រប់ប្រាណជាម្ដង នៅទៀបរបង ខាងពោធិសត្វ ។
ចាប់ដើមអំពី នោះអ្នកទាំង ៣ ឡើងគាល់មហាក្សត្រ ជាមួយ
នឹងពោ- ធិបុរសរ័តន៍ ទោះសារពើគិត ជាមួយផងគ្នា ។
យោបណ្ឌិតំ វិនិច្ឆកន្ទិតំ តតោបញ្ញា នឹងថ្លែងស្រដី អំពី
ប្រស្នា រកអ្នកប្រាជ្ញ សួរបម៉្លេះហោង ។ លុះជាអម្លង់
ឆ្នាំ ១ ព្រះអង្គ ក្សត្រក្សាន្តប្បាស់ប្បង់ ស្ដេចបើកបន្ទូល មធុរ
បង់លង ប្រាជ្ញក្មេងផង ទាំង ៤ អង្គ ។ ថាតែអ្នកប្រាជ្ញ
ទាំងបួនឯងអាច បូរឆ្លើយប្រស្នា អ្វីមួយតិចមិញ ប្រែចេញ
កើតជា ច្រើនក្រៃមហិមា ពេកក្ដាត់កន្លង ។ អ្វីច្រើន
ហើយណា ប្រែវិលកើតជា តិចក្រៃក្ដាត់ហោង បូរអ្នកទាំង ៤
ដោយខ្លួនឆ្លើយស្នង ឥឡូវនេះហោង កុំយូរឡើយណា ។

ព្រះពោធិសត្វ ក្រាបទូលរឹងថ្វាត់ ថារទ្រព្យ អ្នកមាន
សប្បុរស របស់នោះណា តិចវិលប្រែជា ច្រើនពន់ពេកក្រៃ ។
អ្នកឥតសប្បុរស នោះមានរបស់ ច្រើនប្រែវិលវៃ ជាតិចពុំនិត្យ
បូរមហាក្សត្រថ្លៃ ជ្រាបព្រះហឫទ័យ ដំណើរនោះណា ។
សុន្ទរាល័យ ទូលថាគ្រាប់ជ្រៃ តិចហើយប្រែជា ច្រើនក្រៃ
ពេកពន់ ដោយខ្ញុំគណនា ឬស្បីថ្លៃវា ច្រើនហើយតិចវិញ ។
ឥដ្ឋារម្មណ៍ថា ពពុះទឹកវា ច្រើនក្រៃពាសពេញ ទូទាំង
គង្គា ប្រែជាតិចវិញ ស៊ុតត្រីតិចវិញ ប្រែជាច្រើនក្រៃ ។
អភ័យបណ្ឌិត ទូលថាបពិត្រ សម្ដេចជេស្ឋជ័យ កូនគោតិចវា
ប្រែជាច្រើនក្រៃ កូនខ្លានោះនៃ ច្រើនប្រែជាតិច ។ មហាក្សត្រ
ស្ដាប់ហើយ ថាបូរពៅឆ្លើយ អស់អាថិការកិច្ច ប្រាប់ឲ្យ
អញដឹង ដំណឹងសេចគ្រប ដំណើរដូចម្ដេច បូរពៅបរជា ។
អភ័យបណ្ឌិត ទូលថាបពិត្រ សម្ដេចក្សត្រា រីគោមានកូន
បានគេរក្សា មួយឆ្នាំកូនវា តែមួយច្រើនក្រៃ ។ ដ្បិតវារក្សា
រឹងមេខ្លា ប្រសូតពីផ្ទៃ ម្ដង ៥ ម្ដង ៤ ដោយប្អូនទីទៃ
កូនធំហើយនៃ ល្មមលែងបៅដោះ ។ យកកន្ទុយវាត់ កូន

រៀនលោតស្ទាត់ ចាប់ពុំបានស្មោះ មេលោខាំចាប់ សម្លាប់
កូននោះ បោះបង់សៀតសោះ ប្រែជាតិបវិញ ។ ឥដ្ឋារម្មណ៍
ទូល បពិត្រឥស្សូរ រីស៊ុតត្រីមិញ ក្នុងប្លុកនីមួយ ជារយ
ពាន់ពេញ ដល់ញាស់កើតចេញ ច្រើនពន់ពេកក្រៃ ។
ថាបើមនុស្សលោក ពុំចាប់បរិភោគ លោះលែងសព្វថ្ងៃ សម
នឹងបង្អៀត ប្រជ្រៀតជលស័យ ពាសពេញទាំងផ្ទៃ ស្ទឹងបឹង
បិលសា ។ រីពពុះទឹក ច្រើនក្រៃពន្លឹក ពេញទាំងគង្គា លុះ
ខ្យល់បក់មក រលកហើយណា រលាយទៅជា ទឹកប្រែតិច
វិញ ។ សុន្ទរាល័យ ទូលថាគ្រាប់ជ្រៃ តូចប៉ុនល្ងមិញ កាល
ណាជ្រុះបុះ វាដុះឡើងវិញ បែកសាខាចេញ ច្រើនក្រៃ
មហិមា ។ ពុំគួរនឹងគ្រាប់ តូចតិចក្រឡាប់ ជាច្រើនក្ដាត់ណា
ឬស្សីវាផ្លែ ច្រើនប្រែវិលជា តិចវិញហេតុវា សម្លាប់ដើម
អស់ ។ ពោធិសត្វទូល បពិត្រឥស្សូរ ក្សត្រថ្លៃទ្រង់យស
អ្នកឥតធនធាន បើមានសប្បុរស ស្មើមានរបស់ ច្រើនក្រៃ
មហិមា ។ ដ្បិតបានឲ្យទាន ទាននោះជាយាន តែងនាំអាត្មា
រឹតសប្បុរស របស់ច្រើនជា រយពាន់ក្ដីណា ពុំប្រសើរ

ឡើយ ។ ដ្បិតពុំឲ្យទាន ទុកស្មើស្អប់ប្រាណ របស់ឥត
ត្រើយ ពុំជាពំនាក់ សំណាក់បានឡើយ ទ្រព្យនោះឯង
ហើយ ទុកស្មើគ្នានណា ។ បពិត្រភូមី មានក្នុងបាលី ខំពុ
មោសា ទើបអ្នកថ្លាថ្លែង សំដែងគាថា ថ្វាយមហាក្សត្រា
ឲ្យជ្រាបសេចក្តី ។ ធនំអប្បំ បិសាអនំ កបភារី វនិសយោ
ពហុនាបិ អសាធុត វិសាគរំ ។ បពិត្រធនធាន ទ្រព្យនៃ
អ្នកមាន សប្បុរសសេដ្ឋី តិបត្តូបក្តិណា ធ្វើជាទានំ ឲ្យទាន
អស់ទាំង សត្វមយាចកផង ។ ធម៌លោកឧបមា ដូចកល់
គង្គា អណ្តូងគេជីង ពិតពុំហែងហួត រីងស្ងួតឡើយហោង
នៃនរអ្នកផង អាស្រ័យសឹងបាន ។ បើឥតសប្បុរស ទោះ
មានរបស់ ច្រើនក្រៃប៉ុន្មាន ទ្រព្យនោះស្មើក្បួយ អាស្រ័យពុំ
បាន ហេតុពុំឲ្យទាន ធ្វើបុណ្យឡើយនៃ ។ ព្រះធម៌ថែងថា
ដូចកលទឹកមហា សមុទ្រសោតប្រៃ សឹងសូន្យអាសារ ឥត
ការពេកក្រៃ ឥតអ្នកអាស្រ័យ សោះសូន្យជាត្រើយ ។ ដូច
ទន្លេស្ទឹង មានទឹកហើយនឹង ផឹកពុំបានឡើយ ដូចឈើ
បេះតែ ផ្កាផ្លែមកហើយ ពុំស៊ីឯងឡើយ សោះសូន្យទេណា ។

មួយសោតមហាមេឃ ធំក្រៃអនេក បង្អោរគង្គា ដូចឯងពុំបាន សូមទានក្សត្រា អាសារទេណា សូមទានក្សត្រថ្លៃ ។ រឺទ្រព្យនៃអ្នក សប្បុរសជឿងជាក់ ប្រយោជន៍ពេកក្រៃ សាងជាកុសល ជាផលប្រពៃ អ្នកផងប្រាស្រ័យ បានដូចចិន្តា ។ ល្អិតបើធ្លាក់ថ្លស់ ប្រាសលែងរបស់ ពុំបៀតបិន្ទា អ្នកដទៃឲ្យពុំព្រួយទ្បើយណា ពុំបៀតទ្រព្យា អ្នកដទៃទ្បើយ ។ បពិត្រមហារាជ អ្នកទូរជនកាច សាម៉ានតិតត្រើយ បើបានរបស់ស័ក្តិយសច្រើនហើយ ពុំនៅទេទ្បើយ ចិត្តចោរឫស្យា ។ បៀនអ្នកដទៃ ឲ្យគេកើតភ័យ ចិត្តលោភពាលា ល្អិតបើធ្លាក់ថ្លស់ ប្រាសយសទ្រព្យា រឹងជាឫស្យា បៀនអ្នកដទៃ ។ ស្តេចស្តាប់ពាក្យពី ព្រះពង្សពោធិ ទូលដូច្នោះនៃ ទ្រង់ព្រះអំណរ ត្រេកអរពេកក្រៃ បន្ទូលថាហៃ ធនញ្ជ័យបណ្ឌិត ។ អញអរនឹងបា បាមានប្រាជ្ញា ប្រែប្រាជ្ញពេកក្លាត់ ស្តេចដោះប្រដាប់ សំរាប់ពិចិត្រ ពីស្សរង្គតិត ស្វាយប៉ុនកេសី ។ បូជាព្រះពោ- ធិសត្វសេដ្ឋោ រឹងមន្ត្រី អមាត្យយោធា សេនាសេនី សឹងដោះគ្រឿងពី ខ្លួនមកបូជា ។ ពហុបុព្វ តិនិដ្ឋិតិ

រីឯប្រស្នា ច្រើនជាតិបរិញ តិចមិញប្រែជា ច្រើនក្រៃមហិមា សួរបម្លេះនែ ។

បទពំនោលកាល ១ ថ្ងៃ សម្តេចជេស្ឋជ័យ ស្តេចបើក ព្រះកៅរិតា ។ អស់មុខមន្ត្រីសេនា ព្រាហ្មណ៍ព្រឹទ្ធហោរា គង់គាល់អនេកក្រាស់ក្រៃ ។ ស្តេចចង់លងប្រាជ្ញនែ អ្នកប្រាជ្ញទីទៃ បន្ទូលដណ្តឹងប្រស្នា ។ ថាភោន្តោបណ្ឌិតា បិយ បញ្ញា ថាម្នាលអ្នកប្រាជ្ញទាំង ៤ បូរស្រាយប្រស្នាអោយខ្លួន អ្វីមួយហៅសួន ស្រឡាញ់ពេញចិត្តសព្វថ្ងៃ ។ ពោធិសត្វ ទូលក្សត្រថ្លៃ ស្រឡាញ់ខ្លួនក្រៃ ឥតអ្វីនៅស្មើបានឡើយ ។ សុន្ទរាល័យទូលឆ្លើយ ស្រឡាញ់កូនហើយ ក្រៃលែងអស់ទាំងនានា ។ ឥន្ទារម្មណ៍បណ្ឌិតថា ស្រឡាញ់ភរិយា ក្រៃលែងនឹងអ្នកទាំងឡាយ ។ អភ័យបណ្ឌិតក្រាបថ្វាយ បង្គំថា ម្តាយ អាពុកខ្ញុំស្រឡាញ់ក្រៃ ។ ស្តេចស្តាប់អ្នកប្រាជ្ញនោះនែ ឆ្លើយសឹងទីទៃ ៗ ពុំបូលគ្នាឡើយ ។ ស្តេចថាហៃអភ័យអើយ បូរព្រះស្តែងឆ្លើយ ដំណើរស្រឡាញ់នោះណា ។ អភ័យ បណ្ឌិតទូលថា បពិត្រព្រះមហា រាជអើយម្តាយអាពុក ។

មានគុណច្រើនជាន់សាយក់ តែងទីងឲ្យសុខ ឲ្យក្សេមនៃកូន ទាំងឡាយ ។ សឹងរស់ជីវិតដ្បិតម្ដាយ បំបៅឲ្យបាយ បញ្ចុក បំណីនៃបនិត ។ ឥដ្ឋារម្មណ៍រាជបណ្ឌិត ទូលថាបពិត្រ នា ហៅភរិយាប្រពៃ ។ សឹងបិតមូលចិត្តសព្វថ្ងៃ គិតអ្វី ១ ក្រៃ លែងនឹងភរិយាឡើយណា ។ កាលក្មេងនៅនឹងមាតា បិតា រក្សា លុះមានភរិយាហើយហោង ។ រក្សាព្យាបាលស្នេហ៍ស្នង មិនឲ្យមានផ្គង ចិត្តប្ដីដល់ប៉ុនកេសី ។ ប្រពន្ធសព្វថ្ងៃមានប្ដី ស្នេហ៍ស្និទ្ធមេត្រី ប្ដីសោតមានតែភរិយា ។ បពិត្រហេតុនោះខ្ញុំ ថា ចិត្តខ្ញុំស្នេហា ភរិយាក្រៃលែងដទៃ ។ កាលនោះសុន្ទរាល័យ ក្រាបទូលក្សត្រថ្លៃ បពិត្រីមនុស្សទាំងឡាយ ។ កាល ក្មេងអាស្រ័យនឹងម្ដាយ អាពុកពុំឆ្ងាយ ធំហើយអាស្រ័យ ភរិយា ៕ អំណើះលុះចាស់ជរា សឹងផ្ញើអាត្មា ទុកនៅលើ កូនវិញនៃ ។ ហេតុនោះស្រឡាញ់កូនក្រៃ ក្រៃលែងដទៃ ឥតអ្វីនូវស្មើបានឡើយ ។ ព្រះពោធិសត្វឆ្លាស់ឆ្លើយ អាពុក ម្ដាយហើយ សឹងស្រឡាញ់កូនលើសលន់ ។ លុះដល់មាន ប្ដីប្រពន្ធ ទៅឃានតំបន់ ទីទៃស្រឡាញ់ប្រិយហោង ។ រីប្ដី

ប្រពន្ធស្នេហ៍ស្នង ល្អិកបើថ្នាំថ្នង ប្រវ៉ៀងលែងបញពីគ្នា ។
មួយសោតដល់ចាស់ជរា រីក្ដីស្នេហា សោតសឹងឋយស្រ-
ឡាញ់ហោង ។ មួយនីរីក្ខសួនគ្រង ស្រឡាញ់ស្នេហ៍ស្នង
កាលនៅពីក្មេងនោះនៃ ។ លុះធំហើយស្រាកអាល័យ លុះ
ឃ្លាតទីទៃ អាល័យស្រឡាញ់ឋយវិញ ។ បពិត្រីខ្លួនខ្ញុំមិញ
មានចិត្តស្រឡាញ់ ខ្លួនឯងក្រៃលែងដទៃ ។ នោះខ្លួននោះ
ចាស់ហើយនៃ ឃ្លង់ស្រែងវិស័យ បួសពកដំបៅទាំងឡាយ ។
កើតពេញអង្គនេះរូបកាយ ដុំសលាងគិតស្ដាយ ខ្លាចក្រែង
ពិការរូបផង ។ បពិត្រក្សត្រថ្លៃប្ញាស់ប្ញូង ខ្ញុំទូលនេះហោង
មានក្នុងអាថ៌ព្រះបាលី ។ នត្ថិរូបព្យាធិ សមោអរិ លោកថា
សត្រូវពាធា ។ ពុំស្មើព្យាធិបិត្តា បៀតបៀនរូបា ឲ្យជា
អម្ពល់ទុក្ខ ។ នត្ថិវិជាសមំ វិធធនំ លោកថាសម្បត្តិប្រាជ្ញា ។
នត្ថិសមំអត្តា បេមៈលោកថា ស្រឡាញ់ដកដនី ។ បង
ប្អូនសំឡាញ់ភ្ញាប្រិយ៍ បុត្រភរិយាក្ដីពុំ ស្មើខ្លួនឯងឡើយណា ។
នត្ថិកម្មពលា សមំលោកថា កំលាំងពុំស្មើកម្មមាន ។ រក្សា
ផងសព្វឋាន ប្រើយកធនធាន រក្សាសឹងបានប្រពៃ ។

រក្សាភរិយាសព្វថ្ងៃ យកទ្រព្យវិស័យ រក្សាបានបរិបូណ៌ហោង ។
វិវជ្ជនអាស្រ័យទ្រព្យផង ពុំបានឡើយហោង មិនក្រែនឹងកម្ម
បុរាណ ។ មានតែព្រះធម៌ទើបបាន ទៀងតែនាំប្រាណ
ទៅសោយសម្បត្តិទិព្វថ្លៃ ។ រោគាព្យាធិទុក្ខភ័យ កម្មបាប
ផងនៃ ប្រពន្ធកូនការពុំបាន ។ មានតែកុសលសីលទាន
ទើបការរួចបាន រំលងលែងទុក្ខភយា ទើបពោធិសត្វទូលថា
បទមានព្រះបា- លីលោកខ្ញុំនឹងស្មូត្រថ្វាយ ។ ព្រះធម៌សម្មា
ទាំងឡាយ សូមព្រះប្រាជ្ញប្រាយ យកទុកក្នុងព្រះបិត្តា ។
បរោហិតករា ពន្ធពន្ធា បិអហិតោបរោ ។ អហិតោទេហាជោ
ព្យាធិហិតោ ឱសបំអរញ្ញោ ។ អធិប្បាយបទបន្លែ និទានប្រុង
ប្រែ ថាអ្នកដទៃនានា ។ ធើប្រយោជន៍ឡើងណា លោកឲ្យ
រាប់ជា ស្មើញាតិវិស័យឯងហោង ។ បើញាតិពិតពុំស្នេហ៍ស្នង
ទោះប្អូនទោះបង លោកទុកស្មើព្រៃវិញណា ។ ដូចកល
ព្យាធិរោគា បៀតបៀនអាត្មា ប្រែជាសត្រូវវិញនៃ ។ រីថ្នាំ
ដុះនៅនាព្រៃ យកមកអាស្រ័យ ធឹកធីបំបាត់ព្យាធិ ។ ដូច

កលសំឡាញ់ភ្ញាប្រិយ៍ ឲ្យប្រយោជន៍ក្តី លោកទុកស្មើញាតិវិញ ណា ។ រីឯមិត្រផងស្នេហា ទោះបុត្រភរិយា សឹងរៀរអ្នកខ្សត់ឥតទ្រព្យ ។ សឹងចូលបិត្តមូលមកផ្គាប់ នែអ្នកមានទ្រព្យ ធ្វើជាសំឡាញ់ស្នេហ៍ស្នង រីទ្រព្យលោកិយនេះហោង នែនរអ្នកផង ស្រឡាញ់ពំនាក់សព្វថ្ងៃ ។ កាលបើស្លាប់ទៅត្រូវភ័យនរកនោះនៃ អស់ញាតិពុំត្រូវទោសឡើយ ។ រីខ្លួនកាលស្លាប់ទៅហើយ គេបោលឥតត្រើយ កណ្ដាលព្រៃព្រឹក្សស្មសានប្រៀងលានរីលរឹងមកប្ដាន មណ្ឌលទីឋាន លំនៅដោយតួទីទៃ រីមនុស្សក្នុងភពនេះនៃ មានសម្បត្តិថ្លៃ អង្គីពីញាតិឲ្យឡើយ ។ ហេតុផលសាងពីមុនឡើយ ពិតពុំលង់ឡើយ ឲ្យបានដួបក្តីបំណង ។ ទើបពោធិសត្វប្រាស់ប្រៀង ទូលទៅទៀតហោង សំដែងជាបទគាថា ។ អត្ថាតាវេនិវា ឥន្ទេសុសាលោហិតពន្សំ ។ សុខទុក្ខកម្ម គច្ឆអគ្គំ បនគច្ឆតីតិ ។ បពិត្រវិបទបាលី នេះលោកស្រដី ថារីទ្រព្យធនទាំងឡាយ ។ ញាតិសាប់អាពុកនូវម្ដាយ ជូនដល់ព្រៃនាយ ក្រឡាប់មក

ហេនវិញណា ។ មានតែព្រះធម៌គាថា តែងតាមអាត្មា ពុំដែលឃ្លៀងឃ្លាតឡើយហោង ។ ទោះខ្លួនធ្វើបុណ្យបាបផង តាមរក្សាគ្រង នៃខ្លួនបុគ្គលនោះណា ។ ស្តេចស្តាប់ហើយឲ្យសព្វសា- ធុការបូជា ធម៌ពោធិសត្វប្បាស់ប្បង ។ មាស ១ សែនដំឡើងផង អស់មន្ត្រីហោង ឲ្យសាធុការគ្រប់គ្នា ។ បិយតរបញ្ញា និង្ឃិតំដា សួរេបនៅអំបាលនេះហោង ។

( មាគត )

# ពាក្យក្រមន៉ុយ

## ល្បើគរចប្លាប់សង្ឃ

របស់ក្រុមផ្ទុំយ

ខ្ញុំសូមបង្គំព្រះសម្មា សម្ពុទ្ធណា ៗ ក្នុងត្រៃភព បំរើន កម្មដ្ឋានក្រោមពោធិ៍ម្លប់ ធមស្សការគោរពរំឭកគុណ ។ ព្រះ បមបក្រពង្សវង្សម្រ្នីនាថ កំពូលផុតជាតិជាងមហាជន សោយ រាជសម្បត្តិសំបើមបុណ្យ សំបូណ៌លើសលន់លុបលោកា ។ លោកិយដឹងហើយគួរកោតខ្លាច ទ្រង់មានអំណាចព្រះបេស្តា គួរស្តាប់ព្រះរាជឱង្ការ បន្ទូលត្រូតត្រាគួរត្រង់ត្រាប់ ។ ព្រះ ទ័យទ្រង់ត្រេកស្រឡាញ់សង្ឃ ប្រមាណសែនអង្គក្នុងភទ្ទ- កប្ប ព្រះអង្គបានទ្រង់ត្រាស់ប្រញប្តិ ឈ្មោះច្បាប់បា- ដិមោក្ខសំវរសីល ។ បែកបេញជាកងសិក្ខាបទ កំណត់ ពីររយម្ភៃប្រាំពិល មិនឱ្យមាននោះម៉ងមន្ទិល អ្នកប្បួសកុំខ្ជិល កាន់ឱ្យខ្ជាប់ ។ បាណាអទិន្នាជាបឋម ជាតរូបទៀតផ្សំត្រៃ ជា ១០ លោកសង្ឃឥឡូវកាន់មិនសព្វ កាន់ក្នុងបន្ទប់លាយ បន្លំ ។ បន្ទិបលុយកាក់លាក់សម្ងាត់ ទោសត្រូវអាបត្តិលាក់ សម្ងំ បាសកផ្ញើទានគ្មានអារម្មណ៍ សន្សំតែទ្រព្យក្តៅក្រហាយ។

ប្រសិនបើកាន់ច្បាប់ព្រះពុទ្ធ មិនមានធម្មយុត្តិមហានិកាយ បើ
បេះខ្លាបក្រៀងមិនក្លែងក្លាយ សមសុខសប្បាយមិនទាស់គ្នា ។
លោកសង្ឃគ្រប់វត្តមានធំតូច សង្ឃខ្លះវិលខូចសង្ឃខ្លះជា
បរិសុទ្ធប្រាកដទោសគ្រូឧបជ្ឈាយ៍ មានពាក្យគិត្នាតែរាល់វត្ត ។
បាដិមោក្ខពីររយម្ភៃប្រាំពិល លោកសង្ឃណាខ្ជិលចាំមិនស្ទាត់
កងបាចិត្តិយនឹងទុក្កដ ប្លុលមាត់ប្លុលកមិនដឹងខ្លួន ។ ពួក
បាចិត្តិយកៅសិបពីរ និស្សគ្គិយសាមសិបបារាជិកបួន បើបេះ
ហើយចាំឲ្យមាំមួន ល្អបរិសុទ្ធស្លូតឲ្យមិនសាយសុះ ។ ប៉ុន្តែ
សិក្ខាមិនសូវចាំ បំណាំត្រង់ណោះពោលត្រង់ណោះ ត្រង់
ណាដែលដឹងជាខ្លួនខុស ហ៊ានល្មោះពីព្រោះគេមិនដឹង ។
សង្ឃាទិសេសប្រហែសបាន ដប់បីសង្ឃានប្រមាណប្លឹង បើ
ធ្លាប់សង្រួមឲ្យយ៉ាងតឹង មិនអរមិនខឹងមិនបានខុស ។ ឥន្ទ្រីយ
ប្រាំមួយតាំឲ្យភ្លាត់ បាចិត្តិយទុក្កដលាយបំរុះ ត្របៀកអណ្តាត
ភ្នែកច្រមុះ ភ្នែកមើលណោះណោះឃើញសុះសាយ ។
សោតិន្ទ្រិយោស្លូវតិចខ្លាំង ចក្ខិន្ទ្រិយមើលជិតឆ្ងាយ ជិវ្ហិន្ទ្រិយា
ពោលតាយអាយ សើចលេងសប្បាយបំអន់គ្នា ។ បរិសុទ្ធ

អាបត្តិទុក្កដញ៉ាក បារាជិកច្រើនណាស់តែឧបជ្ឈាយ៍ ទ្រព្យក្នុង
សម្បជ្ជិសម្បូណ៌ហៀរ ត្រូវទោសអទិន្នាគរុភណ្ឌ ។ ទ្រព្យ
សង្ឃជាដើមគឺដំណាំ អវហារម្ភៃប្រាំគ្រែគ្នាន់ ឱ្យទុកខ្លះ
ខ្លងក្រែងមិនគ្រាន់ អវហារប្រាំជាន់បារាជិក ។ របស់បាន
ច្រើនក្នុងបំណែក កិបទុកមិនបែកឲ្យលោកភិក្ខុ គ្រឿង
យាវជីវិកឬកាលិក ទុកខ្លួបល្បោបព្រឹកម៉ៅតែឯង ។ ម្យ៉ាង
ទ្រព្យគេហៃបូលវិហារ បាសកបូជាដល់គម្ពែង គេរើបាលី
មានខ្លីវែង គេតែងនឹងហាសង្ឃស្ស ។ ប្រកាសប្រគេនជំនុំ
សង្ឃ បំពោះគ្រប់អង្គហាទេមះ លោកសង្ឃសាធុមិនសល់
ម្នាក់ សង្ឃរាជទុកដាក់មិនបែកបាយ ។ ខុំបាត់បែងតាមខុំ
បេះបាំ អវហារម្ភៃប្រាំបែកបរិយាយ នេះសុទ្ធតែសីលផ្ដួស
អន្តរាយ លោកសង្ឃទាំងឡាយកុំប្រព្រឹត្ត ។ ពីព្រោះឥន្ទ្រិយ
ទាំងប្រាំមួយ លោកណាមិនព្រួយមិនប្រុងគិត លោភោ
មោហោបាំងងងឹត សិស្សមានគំនិតមិនហ៊ានថា ។ សង្ឃ-
រាជគ្រូស្ត្រិសិស្សបរិសទ្យ គួរប្រុងប្រតិបត្តិតាមពុទ្ធដីកា ពួក
បាចិត្តិយសេក្ខិយា កម្រិសង្ឃណារក្សាបាន ។ ញឹកណាស់

តែហ្វូងកងទុក្កដ មិនដឹងកំណត់មាត់ប៉ុន្មាន លោកសង្ឃប្លូល
សិងមិនដឹងប្រាណ ទុក្កដស័ភទសំភកបាំ ។ ក្រវែលដល់
ពេលបាយសំឡ ប្លូលមាត់ប្លូលកពីឆ្វេងស្ដាំ រាងសេក្ខិយាបិត-
សិបប្រាំ បាចិត្តិយបួមប្លាំលើទុក្កដ ។ លោកសង្ឃស្រណុកនឹង
រូបខ្វន បាដិទេសទាំងបួនសិក្ខាបទ បារាជិកបួនមិនកំណត់
បើកាន់ប្រាកដប្រកែកបាន ។ រង្វើលមើលឃើញស្រណុក
គេប កុំឲ្យតៃភ្លេបផ្ទរកម្មដ្ឋាន សង្រ្គមសុបរិតប្រឹតប្រងប្រាណ
អាបត្តិមិនហៅនបួលមកជិត ។ សង្ឃរាជគ្រូស្ងូត្របីសណ្ឋាន
ម្យ៉ាងបួសបង់បាននិព្វានពិត ម្យ៉ាងបួសបង់ប្ដើងដីឡើងរិទ្ធិ
គំនិតបង់ខ្ពស់ក្នុងលោកិយ ។ ម្យ៉ាងបួសមិនត្រង់បង់ធ្វើធំ រៀន
សិល្បអាគមមន្តបាលី ធ្វើពេទ្យព្រោះហោតុបង់ឲ្យល្បី ស្ដោះ
ផ្លុំប្រុសស្រីឲ្យជារោគ ។ ស្ដោះផ្លុំក្រមុំឬមេម៉ាយ មិនដែល
ស្ដោះឆ្ងាយអង្គុយឈ្មោក ដល់មន្តអាគមវាបួលដោក លែង
ស្គាល់ជាលោកជាបាសក ។ ម្យ៉ាងទៀតមារយោទស្រីក្រមុំ
ពោះធំក្នុងពុតបទអាក្រក់ វាផើមវាថាវាកើតត្រាំ កុហកលោក
គ្រូឲ្យប្រកហ្ម៉ំ ។ ប្រកទាល់តែជ្រុលរោគរលួយ រលាយរូប ១

នឹងខន្ធ៥ នេះហៅឫសក្រៅបន្ទូលផ្តាំ ប្រព្រឹត្តសាងកម្មឲ្យ
អន្តរាយ ។ ធ្វើពេទ្យបំពានពាក្យព្រះពុទ្ធ រំលត់រំលាងរាង
រូបកាយ ម្លឹងហើយមិនសិក្ខនៅនឹកស្តាយ សប្បាយចិត្តណាស់
ធ្លាប់ធ្វើធំ ។ ព្រះពុទ្ធមិនហាមឲ្យដាច់សោះ បើរោគបុរសឲ្យ
ស្តោះផ្លុំ កុំភ្លើប្រកបហ្នុំស្រីក្រមុំ រូបក្ខន្ធផ្តើមផ្តុំរលាយស្លាប់ ។
សង្ឃរាជម្យ៉ាងទៀតគ្រប់ដាបី បែកឈានលោកិយធម៌ក្រៅ
ច្បាប់ ពេញភរបរិយាយអធិប្បាយប្រាប់ ឲ្យរៀបប្រដាប់
តាមបំណាំ ។ មានប្រាក់ ១ រៀលសំពត់ស អង្ករនឹងទៀន ៥
ធូប ៥ ពាយសីស្លាធម៌អមផ្លេងស្តាំ ខាបឃើញពៀរកម្មនឹង
បុណ្យបាប ។ គ្រោះហ្នក់យ៉ាងណាមិនកំបាំង ជម្ងឺតិចខ្លាំង
ដឹងជរាប ស្លាប់រស់ដូចម្តេចស្រែបន្ទូរខាប ខ្មោចប្រែតព្រាយ
អាចឃើញទាំងអស់ ។ ឃើញគ្រូអារក្ខបំបួរដួរ ឃើញ
នរកឃើញសួគ៌គ្មានបន្លោះ ឃើញសាយសុះសព្វទ្រព្យរបស់
ជិតឆ្ងាយគៀនកោះធ្លុះក្នុងដី ។ អ្នកខ្លះឲ្យឃឹតរកកូនស្លាប់
ហៅឲ្យមកចាប់កំណើតថ្មី រំលងឆ្នាំពីរឬឆ្នាំបី ប្រុសមកជា
ស្រីខុសប្រាហ្ន ។ នេះឯងធម៌ក្លែងក្រៅគម្ពីរ ឧត្តរិពេញទី

ខុសសិក្ខា វិន័យមិនកាន់ៗតម្រា ពុទ្ធដីកាប្រិតប្រាមមិនព្រម
ស្តាប់ ។ សង្ឃរាជស្លូតត្រង់មានច្រើនវត្ត សូត្រធម៌ចាំស្ទាត់
មិនចាំច្បាប់ បើមានអ្នកបេះរំលឹកប្រាប់ ថាធ្វើតែត្រាប់តាម
គ្រូមុន ។ ប៉ុន្មានតមកដល់ឥឡូវ នឹងរើកត្រូវដូចភ្លេច
គុណ ល្ងង់ហើយមានៈបបេសស៊ុន បាសកធ្វើបុណ្យរាល់វស្ស ។
បំបួសខែជេស្ឋខែអាសាធ បីរនឹងបាត្រខ្នាតមិនត្រូវ ឃើញ
បិនលក់ហោកទិញយកទៅ មិនសូរិះគិតពិនិត្យខ្នាត ។ របស់
ឥឡូវផ្លាស់ប្លែកៗ បាត្រស្ពាន់ដីដែកៗស៊ីវិឡាត ធំជាងឆ្នាំង
បាយហៅថាបាត្រ បានប្រីល្អស្អាតក៏យកដែរ ។ គ្រូសូត្រៗ
ញត្តិតាមបន្ទូល បាសកលួនបួលប្រគេនតែ លោកសង្ឃ
អង្គុយរៀងបង្ហែ បាសកបិនខ្មែរទាំងក្មេងចាស់ ។ អង្គុយ
ជ្រកប្រៀតនឹងលោកសង្ឃ មិនបង់ឲ្យឆ្ងាយឲ្យស្រឡះ លុត
ក្រាបប្រណម្យឱនសំពះ អន្តរាយហត្ថបាសខូបលោកសង្ឃ ។
អ្នកបួសមិនកើតឧបសម្បទ បរិសទ្យអង្គុយនឿយគ្រប់អង្គ
គ្រូសូត្រនឿយសូត្រគួរផ្តើតផ្តង់ ប្រឹងប្រិតជម្រង់ជម្រូវខ្យល់ ។
ច្បាប់បួសត្រូវគ្នានឹងកបិន តែបេះមិនឆ្អិនមិនឡើងផល គួរ

រៀនឱ្យសព្វកុំឱ្យឆ្គល់ បើរៀនបេះដល់ត្រូវសមគ្គា ។ លោក
សង្ឃវត្តក្រៅទៅជួយបុណ្យ បើបាននិមន្តចូលវិហារ ត្រូវគង់
ប្រជុំរួបរួមគ្នា កុំឱ្យឃ្លាតឃ្លាពីហត្ថបាស ។ លោកសង្ឃ
រៀបសូត្រអង្គកឋិន បាសកខ្មែរចិនទាំងក្មេងចាស់ ត្រូវថយ
ឱ្យឆ្ងាយឱ្យស្រឡះ កុំឱ្យពាល់ប៉ះនឹងលោកសង្ឃ ។ សូត្រ
ស្រេចគ្រងស្រេចសូត្រសន្មត ឱ្យឮប្រាកដលោកគ្រប់អង្គ
មិនត្រូវសូត្រខ្សឹបខ្លាចគេប្លង់ ត្រូវឱ្យអស់សង្ឃដឹងរាល់គ្នា ។
សូត្រក្រាលក័ង្កបសូត្រសន្មត ឱ្យឮប្រាកដក្នុងវិហារ មាន
កាលលោកគ្រូធំឧបជ្ឈាយ៍ បិត្តជាបែកឱ្យគ្រូសូត្រគ្រង ។
បើគ្មានលោកគ្រូមានលោកចាស់ គោរពសំពះកុំរំលង ត្រូវ
សូត្រភ្តេតាមទំនង ក្រាលគ្រប់ពីរជិងប្រាប់បរិស័ទ្យ ។
លោកចាស់វស្សាមិនបានគ្រង គ្រាន់តែផ្ដុំផ្គងរៀបបែកបាត់
អានិសង្សកឋិនបាំងអាបត្តិ បង្ហាត់សូត្រធម៌ឱ្យល្អបគ្នា ។
ក្រាលគ្រប់ឈប់ស្ងេះ ១ ស្របក់ បាសកប្រគេនអស់ភ័ស្តុភារ
បំពោះរាល់អង្គក្នុងវិហារ អាមិសបូជាគ្រប់ប្រដាប់ ។ ប្រគេន
រួចហើយចូលជិតបុះ ទាំងស្រីទាំងប្រុសមិនខុសច្បាប់ ប៉ុន្តែ

អ្នកធ្លាយច្រើនប្រញាប់ មិនសូវចាំស្តាប់លោកយថា ។
សូមទានសន្តោសសម្តែងច្បាប់ ព្រះសង្ឃកុំចាប់ចងទោសា
ខ្ញុំភ័យខ្លាចអាប់ព្រះសាស្នា ប្រោសប្រាណមេត្តាបណ្តា
សង្ឃ ។ ខ្ញុំពោលមិនមានពាក្យបង្កាប់ ក្រែងសីលលោក
ដាច់ខ្ញុំដម្រង់ ដម្រូវតែតាមច្បាប់ព្រះអង្គ ព្រះឱស្ឋត្រឹមត្រង់
ត្រូវមាត្រា ។ កាលអង្គសម្តេចព្រះចមភព ជាម្លប់មនុស្សសត្វ
នឹងទេវតា ជិតចូលនិព្វានមានពុទ្ធដីកា ផ្តាំផ្ញើសាស្នាមហា
បរិស័ទ្យ ។ ភិក្ខុភិក្ខុនីអង្គអរហន្ត អានន្ទមិនទាន់បានអរ-
ហត្ត រក្សាវិន័យកុំឲ្យបាត់ ប្រយ័ត្នឲ្យមានប្រយោជន៍យូរ ។
ក្រោយនោះព្រះអង្គចូលនិព្វាន អរហន្តហោះហ្វានមានជាគ្រូ
មិនមានអក្ខរាណាដាក់ទូ ទេស្នាបង្ហូរពីព្រះឱស្ឋ ។ ព្រះ
អគ្គសាវ័ករាល់ព្រះអង្គ ព្រះទ័យស្រោចស្រង់ទ្រង់សន្តោស
សម្តែងធម៌អាចិមេត្តាប្រោស បាបបុណ្យគុណទោសនឹងសីល
ទាន ។ ឈ្វេងយល់ថាធម៌នឹងសូន្យស្ងាត់ អស់អង្គអរហត្ត
ចូលនិព្វាន សង្ឃសេខបុគ្គលមិនទ្រង់ញាណ នឹងមានអក្ខរា
ណាតែងទុក ។ ព្រះធម៌ប្រាំបីហ្មឺនបួនពាន់ ស្រេចនៅ

អានន្ទបាំទុក ដំណែលព្រះអង្គដឹងគ្រប់មុខ ជង្រុកធម៌អាថ៌
មហាអានន្ទ ។ ជាព្រះអនុជអាណិតសត្វ ក្រែងបាត់ធម៌
អាថ៌មិនគ្រប់គ្រាន់ ព្រះធម៌ប្រាំបីហ្មឺនបួនពាន់ គ្មេរគ្មាន់ខ្ទះ
ខ្ទេងបាត់បែងបារ ។ បេះបប់អភិធម្មបាំរហូត វិន័យព្រះសូត្រ
៥ ប្រការ ប្រកាសអស់អង្គអរហន្ដា បិដកឯណាជាឫស
គល់ ។ បរមត្ថព្រះសូត្រអានន្ទបាំ វិន័យទាំង៥ឧបាលីយល់
អរហន្ដទាំងអស់កើតរវល់ អំពល់អំពីរឿងធម៌អាថ៌ ។ ព្រះបាទ
អជាតសត្រូវ ជួយគិតជម្រើវព្រះសាស្នា សន្មតឲ្យឈ្មោះហៅ
ក្សត្រា ព្រោះមហាក្រស័ត្របួលគំនិត ។ និយាយឲ្យដឹងដើម
កំណើត កាលកើតអក្ខរាបារស្លឹករឹត បកប្រែបាលីសេចក្ដីពិត
ពិនិត្យត្រឹមត្រូវតាមពុទ្ធដីកា ។ ប្រាំរយឆ្នាំគត់ផុតភិក្ខុនី
មនុស្សស្រីលែងបួសខ្លាបសិក្ខា កំណាត់មួយពាន់ឆ្លាយ
វស្សា អស់អរហន្ដាបួលនិព្វាន ។ នៅសល់តែសង្ឃបុ-
ថុជ្ជន កិលេសនៅធ្ងន់នៅស្រែកឃ្លាន សង្វាតឱហាតបំរើន
ឈាន ហោះធ្យានមិនរួចដូចបំណង ។ កើតមានគម្ពីរនៅ
លង្កា ព្រះពុទ្ធឃោសាបារបម្លង កើតមានបាលីសម្រាយផង

ធ្វើបុណ្យម្តងៗ ស្តាប់ទេស្នា ។ ទសជាតិទាំង ១០ មាន
គ្រប់វត្ត ប្រែត្រូវប្រាកដព្រះគាថា ព្រះធម៌សូត្រមន្តឬសូត្រជារ
អ្នករៀនអក្ខរាពីរបំណែក ។ បំណេះបំណាំបាំរាល់ខ្លួន អ្នក
រៀនវានក្បួនចាស់បារបែក ហ៊ានភ្នាល់ព្រោះអាងឃើញនឹង
ភ្នែក កើតឈ្លោះប្រកែកប្រកួតខឹង ។ ប្រកាន់តែខាងខុស
រហូត មិនរៀនមេសូត្រឲ្យបេះដឹង អាងបេះតែកកាប៉ុណ្ណឹង
ខំប្រឹងបំអឹតអួតខ្លួនត្រូវ ។ សព្វថ្ងៃជជែកពីយោ-យ៉ោ ជំទ្បើង
ភ្នែកស្មោមុខក្រញូវ ថាធ្លាប់យោន ពីខ្មោចឪ តទ្បូរយ៉ោណា
មិនសុខចិត្ត ។ អ្នកម្ខាងអាងស្រះត្លប្រាំបី ឲ្យនឹងបាលីជាកំរិត
ផ្សំគ្លមេសូត្រប្រឹងប្រែប្រិត ព្រោះផ្សិតឲ្យត្រឹមត្រូវមាត្រា ។
អ្នករៀនគ្រប់វត្តគ្រប់នគរ សជាក់ជើងលរាប់ស្លូស្លា បើសនឹងមុ
រាប់ស្នូស្នា អ្នកមានប្រាជ្ញាគួរស្តាប់បាន ។ កុំល្ងង់ទាល់ងាប់
ធ្លាប់មិនដឹង បើខឹងខំឃាត់ថាឲ្យខាន ខជាក់ជើងមពីបុរាណ
ក្មេងតូចប៉ុន្មានស្គាល់ខ្លា ។ រាល់រាស្ត្រចាស់ក្មេងកុំបិត្តខ្លាំង
គួរខ្លាសបារាំងអ្នករាជការ ដើមហេតុអំពីព្រះករុណា ឲ្យសាង

សាសាប្រែបាលី ។ ទ្រង់ហាំទំនៀមពីបុរាណ ហើយបាន
ជំនុំព្រមកុង្សីយ៍ បំណាច់ធ្វើស្តេចគ្រងផែនដី ទិសទាំងប្រាំបី
រពៃគ្រប់ ។ ព្រះកាយពលមិនរវល់រែក ព្រះទ័យរំលែកទាំង
ថ្ងៃយប់ ចូលទៃគបន្ទំទីបន្ទប់ បន្ទូលមិនឈប់រាល់វេលា ៗ
មេត្តាប្រោសប្រាណអ្នកមានសក្តិ បែកលុយបែកកាក់គ្រប់ភ្នាក់
ងារ ម្យ៉ាងត្រួតក្សត្រីស្នំស្រិង្គារ ក្រែងគ្រូនវងាមិនបានសុខ ។
ព្រះទ័យមេត្តាសព្វមនុស្សសត្វ សោយរាជសម្បត្តិសំបើមស្តុក
ព្រះកាយប្រកបគង់ស្រណុក ព្រះទ័យរីតុក្កជាធម្មតា ។
១ ព្រួយនឹងឱបព្រះនគរ ២ ព្រួយនឹងពព្រះសាស្នា ៣ ត្រួត
លោកសង្ឃកាន់សិក្ខា សង្រ្គមកិរិយាមិនបរិសុទ្ធ ។ ងើយ
ណាស់ព្រះនេត្រព្រះកាំម៉ា ព្រះឱស្ឋត្រួតត្រាតឿនបំផុត ងាស់
តឿនបំភ័យពួកកុលបុត្រ ឲ្យបេះលំឱតសង្រ្គមកាយ ។
ទ្រង់បេញប្រកាសដាក់ប្រាកង ប្រគល់រាល់វត្តទោះជិតឆ្ងាយ
លោកសង្ឃមិនត្រូវស្រើបសប្បាយ អស់ល្បែងទាំងឡាយគ្រប់
ជំពូក ។ មិនត្រូវបំពោះស្តាប់តន្ត្រី កុំបីមើលរាំរាំនាំភ្លូក
កុំដើរភ្លើៗមើលអុំទូក អ្នកបួសធ្វើលោកមិនត្រូវការ ។ បើ

មានត្រូវកិច្ចដើរយប់ថ្ងៃ   សង្ឃបងនិស្ស័យចាស់វស្សា   កុំដើរ
ទឹមស្មើទៅណា ៗ អ្នកបេះសិក្ខាគេទាស់ភ្នែក ។ លោកនេន
កុំសុំលុយបិនបាយ   បិណ្ឌបាតតែបាយម្នាក់ ១ វែក   គ្រឿង
ម្ហូបបំណាំបាសកបែក   កុំឃ្លួរពុនវែកវាហោករីក ។ របស់
បាសកគេប្រគេន   ប្រគល់លោកនេនបានលោកភិក្ខុ   បិញ្ចឹម
ជីវិតនឹងបាយទឹក   បិណ្ឌបាតពេលព្រឹកឃ្លប់ស្លូត្រៀន ។
លោកណាត្រឹមត្រូវមិនសូវខុស   ស្ងៀមស្ងាត់ទៅចុះកុំអន់អៀន
លោកណាមិនបេះកុំរេះរៀន   ពាក្យប្រៀនប្រដៅឲ្យផ្អើលភ្ញាក់ ។
បំណាច់ព្រះអង្គទ្រង់ផ្តាំផ្ញើ   សាស្នាឋិតលើស្តេចមហាចក្រ
ព្រះមហោបមពង្សទ្រង់ជំពាក់ បំពោះធុរៈនឹងសាស្នា ។ ពីត្រឹម
ណោះរៀងដរាបមក   ដល់ស្រុកគោកធ្លកមានសារិតារ   ប៉ុន្មាន
រាជ្យហើយមិនដឹងជា   ដល់មកករុណាយើងសព្វថ្ងៃ ។ ហេតុ
នេះលោកសង្ឃប្រុងពិនិត្យ សៀវភៅស្លឹករឹតមានរាល់ដៃ   ផ្ទៀង
មើលសុភោកវិនិច្ឆ័យ   បើនៅសង្ស័យឲ្យសិក្សា ។ សព្វសង្ឃ
ចាស់ខ្ចីគប្បីស្តាប់   ឈ្មោះច្បាប់បំពានព្រះពុទ្ធដីកា   បង្គំថ្វាយ
ដល់ព្រះករុណា សូមទ្រង់មេត្តាជ្រាបព្រះទ័យ ។ ក្រែងប្អូនប្រទុះ

ពាក្យផ្តាំផ្តួង ពុំត្រូវទំនងក្រិត្យវិន័យ សុំទ្រង់មេត្តាអត់ទោស
ពៃរ៍ ក្រញ្ញក្រាបសិរសីក្រោមព្រះបាទ ។ ព្រះសង្ឃទាំងអស់
ទោះតូចធំ ខ្ញុំឱនបង្គំសុំអនុញ្ញាត ខ្ញុំពោលមិនមានពាក្យប្រមាទ
សង្ឃជាល្អស្អាតខ្ញុំមិនហ៊ា ។ ខ្ញុំពោលតែសង្ឃផ្ញើអាក្រក់ បើ
ខ្ញុំកុហកខ្វបមុសា ហេតុនេះខ្ញុំសុំបវារណា សង្ខេបគិដ្ឋិតារឿង
លោកសង្ឃ ។ សុំក្រើនរំលឹកឬកឃាសក ប្រើនបិត្តអាក្រក់ខ្ញុំ
ដម្រង់ ដម្រើតាមផ្លូវច្បាប់ព្រះអង្គ កុំបីលះបង់បោលសាស្នា ។
កើតមកពូជពង្សពេញពុទ្ធសាស្ន៍ កុំភ្លើកុំភ្លាស់ភ្លេចសារិតារ
មានរូបមានបិត្តមានប្រាជ្ញា គួរពិចារណារកខុសត្រូវ ។ កាល
កើតមិនទាន់ដឹងទោសទុក្ខ បន្ទោរមូត្រល្មកដាក់ម៉ែឪ លាង
ជុំសជ្រះស្អាតផ្តេកទុកនៅ បុកត្រូវអង្គរស្ងួដណ្ដាំ ។ ដេកឱប
គ្រុបក្រុងប្រុងប្រយ័ត្ន ក្រែងសត្វស្រមោចមូសបុចខាំ លំបាក
នឿយណាស់ ១៥ ឆ្នាំ ម៉ែឪរងកម្មបីញ៉ឹមកូន ។ កំឡោះក្រមុំ
ពេញរូបកាយ អាពុកនឹងម្ដាយបាស់ទ្រមខ្លួន ក្រមុំរូបល្អ
បរិសុទ្ធស្ងួន្យ បានស៊ីជំនូនចំណី ។ រៀបការរកស៊ីរួមបន្ទុក
ស្ងួមម្ដាយឪពុកប្រពន្ធប្ដី មួយឆ្នាំពីរឆ្នាំកើតកូនខ្ចី ជីដូនតាបី

បៅដុះដាក់ ។ កាលកូនពីតូចនៀយផុសលាង ធំពេញរូបរាង ខានប្រែឡក់ លាងល្អក់ចៅទៀតឡើងពីរថ្នាក់ កម្មមានជំពាក់ ថែមពីរដាន់ ៗ បំណែកកូនប្រុសបានបួសភិក្ខុ ខ្លះបួសរៀន សប្បាយស្ងន់ សឹកមកអឹងឈប់ទៅភប់ភ័ន្ត រៀបការមិនទាន់ រាន់ចិត្តឯង ។ អ្នកខ្លះបួសបេះដឹងធម៌អាបិ ប្អូនប្រាំស្បាយយូរ អង្វែង សឹកមករកស៊ីខ្វះខ្វែង មិនលែងឲ្យទុក្ខឪពុកម្ដាយ ។ ព្រួយចិត្តព្រោះផ្សិតរកប្រពន្ធ ថែមទោសទុក្ខធ្ងន់រាល់រូបកាយ រកស៊ីនៅជិតមិននៅឆ្ងាយ កូនធ្វើខ្ញុំម្ដាយៗខ្ញុំកូន ។ បើមាន ប្រពន្ធនៅស្រុកឆ្ងាយ ឪពុកនឹងម្ដាយឃ្លាតដោយខ្លួន មាន ម្ដាយខាងស្រីនៅថែប្អូន មិនលែងជីដូនធ្វើខ្ញុំចៅ ។ ពីព្រោះ រកស៊ីក្នុងបន្ទុក បំណើគ្រប់មុខទោះឆ្ងាយនៅ ស្វាយខ្នុរបេកដូង ដំឡូងត្រាវ របស់នោះមៅក្នុងបំណែក ។ អាពុកម្ដាយចាស់ ឈឺទម្ងន់ បំណើដោរផន់ជូនដាប់ប៉ែក លើកឡើងប្រគល់ម្ដាយ ប្រកែក សម្រិក់ទឹកភ្នែកស្ដាយបំណើ ។ ចង់ដែរប៉ុន្តែលេប មិនរួច ជិបបានតិចតួចបោលទៅដី យ៉ាងនេះគ្រប់មនុស្ស ទាំងប្រុសស្រី គប្បីសំគាល់រាល់រូបកាយ ។ ពីតូចទាល់ធំ

ពេញបំណាស់ មិនដែលសំពះអាពុកម្ដាយ សំពះម្ដងៗ តែអ្នកឆ្ងាយ ត្រង់ម្ដាយអាពុកជាអៀនខ្មាស ។ ម្ដាយរលត់វេលាណា អាហារស្រោបទឹកលើកបំអាស ប្រអូលប្អូលដុសលាងជិរះ ឲ្យក្រាបសំពះបវារណា ។ ប្រណាម្យសុំទោសម្ដាយមិនដឹង ត្រង់អរឬខឹងម្ដាយមិនថា គ្មានប្រាក់ទៅជឿទំនិញផ្សារ ខ្លះខ្ចីបងការញាតិសន្ដាន ។ មានតែកំលាំងតាំងខំរត់ទៅទិញសំពត់ផ្ដិលជាសបាន គប់គ្រឿងប្រដាប់ទាំងប៉ុន្មានឲ្យបានដាក់ផ្លុងឲ្យម៉ែឪ ។ ដាក់ហោលបោះបង់លោកសង្ឃទស់បើឲ្យកាលរស់នោះពេញត្រូវ ជវ័នវិញ្ញាណចេញអស់ទៅ អ្នកណានឹងនៅនឹងត្រេកអរ ។ កាលម្ដាយរស់នៅមិនសូវលុះ បាននេះខ្វះនោះបេះតែក្រ ម្ដាយស្លាប់មិនដឹងប្រឹងត្រដរ អង្វរខ្ចីជឿគេធ្វើបុណ្យ អ្នកមានសំណាងប្រសើរគាប់ បុគ្គលមានភ័ពមានទ្រព្យធន គេនឿយតែទិញទូលរ៉ែកពុន មានប្រាក់ជាទុនធ្វើជាទាន ។ ច្រើនចិត្តអាក្រក់តិចចិត្តល្អ ច្រើនខាងអ្នកក្រតិចអ្នកមាន កំណាញ់ស្វិតពេកច្រើនស្រែកឃ្លាន គួរ

គិតសន្និដ្ឋានបួលបិដ្ឋបុះ ។ កើតមកតែងរកប្រពន្ធប្ដី មួយរយ
មានពីរបីទាំងស្រីប្រុស បើប្ដូសត្រឹមត្រូវមិនសួរខុស ស្លាប់
រស់កុំសិកយកប្រពន្ធ ។ បើទ្រាំមិនបានហើយសឹកមក ឲ្យ
គិតលៃលករកទ្រព្យធន ជូនម្ដាយអាពុកទុកធ្វើបុណ្យ គោរព
តបគុណបំរើនផល ។ បើយកប្រពន្ធនៅឲ្យឆ្ងាយ ល្មមម្ដាយ
អាពុកទៅមកដល់ កុំនៅជាមួយកើតអកុសល ព្រោះម្ដាយ
ក្ខាយខ្វល់ទឹងកូនឯង ។ ប្រពន្ធនឹងប្ដីស្រីនឹងប្រុស មិនដឹង
ទោសខុសគ្រប់កន្លែង គ្មានប្ដីប្រពន្ធគេហៅថ្លែង អ្នកប្រាជ្ញ
សំដែងថាសេសបាប ។ យើញត្រូវតែនៅឃ្លាតដោយខ្លួន
បំណាំជំនួនជូនជរាប កុំនៅជាមួយកើតផ្ទេះផ្ទាប លុតក្រាប
សំពះកុំក្ខាសគុណ ។ កូនចៅខាងក្រោយឲ្យប្រដិបត្តិ ប្រយ័ត្ន
កុំធ្វើដូចអ្នកមុន អ្នកមានកូនចៅបានជាស៊ុច ទោសធ្ងន់ឲ្យ
ទុក្ខអាពុកម្ដាយ ។ ស្រួលណាស់តែនៅឃ្លាតដោយខ្លួន ឲ្យ
បេះថៃធ្លូនមើលឆាយអាយ ផ្ទះធំស្រណុកសុខសប្បាយ កុំ
ស្ដាយស្រណោះរបស់ទៅ ។ មេបាសុខចិត្តឲ្យកូនស្រី យើង

សង់ផ្ទះថ្មីជួបម៉ែឪ មេបារៀបការជាត្រឹមត្រូវ ខ្លួននៅមិននៅ នោះតាមចិត្ត ។ ប៉ុន្តែម៉ែឪត្រូវសប្បុរស ឲ្យទ្រព្យរបស់ព្រោះ អាណិត ធ្វើតាមទំនៀមច្បាប់ក្រមក្រិត្យ សាច់សាលោហិត មានសង្ស័យ ។ យើងខំរកស៊ីមានពេលឈប់ គួរឆ្លៀតគោរព ទោះយប់ថ្ងៃ បំណីផ្អែមឆ្អាបទោះសាបប្រៃ កុំលាក់សំបែស៊ី ភ្លេចគុណ ។ ខ្លួនខ្ញុំកំណើតរាស្ត្រអ្នកស្រែ ឆោតឆៅខ្លៅដែរ ពីកាលមុន កាលមកពីបួសខំរែកពុន ធ្វើបាបនឹងបុណ្យទម្ងន់ ស្មើ ។ ខ្ញុំស្មោះគោរពអាពុកម្តាយ អស់លោកទាំងឡាយល្មម សរសើរ ខ្ញុំជួនដំណឹងតាមដំណើរ ព្រោះខ្ញុំគ្រាន់បើជាងអ្នក ល្ងង់ ។ ជាតិក្រោយកុំឲ្យខ្ញុំល្ងីល្ងើ ជាតិនេះបាស់ស្មើរខ្ញុំប្រឹង ស្ទង់ ប្រឹងស្ទុះឲ្យរួចពីអន្លង់ ភ័យភិតខ្លាចផុងទៅក្នុងផុក ។ ក្នុងភពសង្សារខ្ញុំសង្ស័យ សព្វថ្ងៃខ្ញុំភ័យខ្លាចនរក ម្យ៉ាងទៀត ខ្តើមជាតិអាជីវក ជាតិល្មោភហួបល្មក់ព្រោះល្មើសគុណ ។ ក្រែងខ្ញុំបានល្មើសម៉ែឪខ្លះ ខ្ញុំភ័យខ្ញុំណាស់ក្រែងខ្ញុំស៊ុន ខ្ញុំសុំ ស្មាលាទោសពីមុន សុំបុណ្យជួយបាំងបាបឲ្យបាត់ ។ ឲ្យ

បានទាន់តួព្រះស្រីអារ្យ ឲ្យបែកប្រាជ្ញាក្នុងបរមត្ថ ព្រះអង្គទេស្នា
ទ្រង់ប្រោសសត្វ សុំលុះអរហត្តដូចបំណង ។ បំណែកខ្ញុំ
ផ្សាយច្បាប់រំលឹក អស់លោកជួយនឹកសច្ចាផ្សង ធ្វើបុណ្យ
បែកផលដល់ខ្ញុំផង នឹកឈ្មោះម្តង ៗ ដូចធម្មតា ។ មាន
ម្តាយអាពុករាល់រូបរាង គោមជុះជុសហេងគួរល្មើមល្អ ព្រះ
ពុទ្ធបាកផុតវដ្តសង្សារ ប្រាថ្នារកផ្លូវទៅនិព្វាន ។ រលាយ
កង់ទុក្ខអកុសលកម្ម រលត់ខន្ធប្រាំលែងស្រែកឃ្លាន យើងនៅ
សង្ខារនឹងវិញ្ញាណ ទោសទុក្ខតែងមានតែរាល់គ្នា ។ ខ្ញុំទូល
បង្គំដើមឈ្មោះអ៊ូ ពូជពង្សអំបូរខ្មែរអ្នកជា អាពុកឈ្មោះអុក
មានសក្តិងារ ហៅពញាធម្មជារាធ្វើមេស្រុក ។ ក្នុងខេត្តភ្នំ
ពេញឃុំកំបូល ពូជពង្សត្រកូលម្ចាស់អង្គប៉ុក អាពុកអ្នកម្តាយ
ឈ្មោះពញាម៉ុក គាត់ធ្វើមេស្រុកឃុំស្ពានឫ ។ អ្នកម្តាយអា-
ពុកបងប្អូនជិត ជិទួតមួយពិតពូជបិត្តល្អ ដូនតាផ្សំផ្គុំជាដំណា
បង្កកើតខ្ញុំទូលបង្គំ ។ បង្កើតអំពីក្នុងគំនិត ភ័យភិតខ្លាចបាប

បង់បាតបុណ្យ  បានបែកបែងច្បាប់ប្រាប់មហាជន  ប្លូនច្បាប់
ពីមុនជូនរាជការ ។ បោះពុម្ពសៀវភៅបែកសព្ទសាយ  ម៉ាដឹមូ-
ហៀលបាត់ថ្វាយព្រះករុណា  មិនបានថ្វាយផ្ទាល់ដល់ហត្ថា
សូមទ្រង់មេត្តាប្រោសប្រណី  ឱកាយប្រណាម្យសុំអនុញ្ញាត
ក្រាបក្រោមព្រះបាទព្រះបារមី បែងច្បាប់បរមត្ថអត្ថបាឡី សេចក្តី
បែងបប់ម្ល៉េះហើយហោង ។